**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


## សារណាបញ្ចប់ការសិក្សា

# ស្ត្រីលើកកម្ពស់ជីវភាពគ្រួសារតាមរយៈ សេដ្ឋកិច្ចក្រៅប្រព័ន្ធ

ករណីសិក្សា៖ ស្ត្រីលក់ភេសជ្ជៈតាមរទេះក្នុងរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ប៊ុន សេខ**

**អាន គឹមស្រ៊ី**

សាស្ត្រាចារ្យណែនាំ

លោក **ទួន ផល្លា**



ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី១៦

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

## សារណាបញ្ចប់ការសិក្សា

# ស្ត្រីលើកកម្ពស់ជីវភាពគ្រួសារតាមរយៈ សេដ្ឋកិច្ចក្រៅប្រព័ន្ធ

ករណីសិក្សា៖ ស្ត្រីលក់ភេសជ្ជៈតាមរទេះក្នុងរាជធានីភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ម៉ុន សេង**
**អាន គឹមស្រី**

សាស្ត្រាចារ្យណែនាំ
លោក **ទួន ផល្លា**

ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច    ឆ្នាំចូលសិក្សា ២០១៣
ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី១៦    ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ប៊ុន សេង** និង **អាន គឹមស្រី** ជានិស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី១៦ (សិក្សាបង់ថ្លៃ) ក្នុងឆ្នាំសិក្សា ២០១៦-២០១៧ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅ និងថ្លែងអំណរគុណចំពោះ៖**

– លោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីរ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់មើលថែរក្សាយើងខ្ញុំតាំងពីតូចរហូតដល់ធំដឹងក្តី។ លោកទាំងពីរបានប្រឹងប្រែង តស៊ូពុះពាររាល់ឧបសគ្គក្នុងការប្រកបរបររកស៊ីដើម្បីបានកម្រៃក្នុងការផ្គត់ផ្គង់ការសិក្សាយើងខ្ញុំ ក្នុងគោលបំណងតែមួយគត់គឺចង់ឱ្យយើងខ្ញុំទទួលបានចំណេះដឹងជ្រៅជ្រះ ដែលជាទុនដ៏ចាំបាច់ក្នុងជីវភាពរស់នៅក្នុងសង្គម។ មិនត្រឹមតែប៉ុណ្ណោះ លោកតែងតែជំរុញ និងលើកទឹកចិត្តយើងខ្ញុំជានិច្ចឱ្យជម្នះរាល់ឧបសគ្គក្នុងការសិក្សា ដើម្បីទទួលបានផ្លែផ្កាដ៏ល្អនាពេលអនាគត។

– ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យ ទាំងអស់ដែលបានផ្តល់នូវចំណេះដឹងដែលកាត់ថ្លៃពុំបាន និងចែកចាយនូវរាល់បទពិសោធន៍ដែលលោកធ្លាប់បានឆ្លងកាត់ដល់យើងខ្ញុំ។

– លោកសាស្ត្រាចារ្យ ទូន ផល្លា ដែលជាសាស្ត្រាចារ្យណែនាំ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយជ្រោមជ្រែង ណែនាំ និងផ្តល់ជាគំនិតនិងមតិយោបល់ល្អៗ ដល់យើងខ្ញុំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះបានដោយជោគជ័យ។

– មិត្តភក្តិមួយចំនួន ដែលបានសហការក្នុងការចុះជួយសម្ភាសន៍យកព័ត៌មានពីអាជីវករដែលប្រកបរបរលក់ភេសជ្ជៈតាមរទេះ។

– បងៗ មីងៗ និងអ៊ុំៗ ដែលជាអាជីវករប្រកបរបរលក់ភេសជ្ជៈតាមរទេះ ដោយបានចំណាយពេលវេលាក្នុងការផ្តល់ព័ត៌មានយ៉ាងក្បោះក្បាយដល់យើងខ្ញុំ។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរដល់លោកអ្នកទាំងអស់ ឱ្យសម្រេចជោគជ័យគ្រប់ភារកិច្ច និងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ចំណេះវិជ្ជា គឺជាទ្រព្យជាប់នឹងប្រាណដ៏មានតម្លៃដែលមនុស្សគ្រប់រូបប្រាថ្នាចង់បាន ហើយយើងអាចទទួលបានតាមរយៈការក្រេបជញ្ជក់ចំណេះដឹងពីការសិក្សារៀនសូត្រ។ ប៉ុន្តែ ការសិក្សាតែក្នុងសាលាមិនអាចឱ្យយើងទទួលបាននូវចំណេះដឹងគ្រប់គ្រាន់បានឡើយ។ ដើម្បីក្លាយខ្លួនជាបុគ្គលម្នាក់ដែលមានចំណេះដឹងច្រើន និងទទួលបានជោគជ័យ វាទាមទារឱ្យអ្នកសិក្សាទាំងអស់សិក្សាស្រាវជ្រាវបន្ថែមទៀត។ ផ្អែកលើហេតុផលទាំងនេះហើយ ក្រោយពីបានឆ្លងកាត់នូវការសិក្សាអស់រយៈពេលជិត៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច យើងខ្ញុំទាំងពីរនាក់ដែលជាសិស្សរួមជំនាន់គ្នា បានពិភាក្សា និងសម្រេចចាប់ដៃគូគ្នា ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៧នេះ ដោយពួកយើងសង្ឃឹមយ៉ាងមុតមាំថា នឹងបានសិក្សាស្រាវជ្រាវបន្ថែមទៅលើចំណុចដែលយើងខ្វះខាតក្នុងការសិក្សានៅក្នុងថ្នាក់ ក៏ដូចជាក្នុងសាលា។

ជាមួយគ្នានេះដែរ ពួកយើងក៏បានជ្រើសរើសនូវប្រធានបទមួយដែលទាក់ទងនឹង **ស្ត្រីលើកកម្ពស់ជីវភាពគ្រួសារតាមរយៈសេដ្ឋកិច្ចក្រៅប្រព័ន្ធ**។ មូលហេតុដែលជំរុញឱ្យពួកយើង ជ្រើសរើសប្រធានបទនេះ ក៏ព្រោះតែយើងខ្ញុំមានគោលបំណង ចង់សិក្សាស្វែងយល់អំពីស្ត្រីនៅកម្ពុជាជាពិសេសស្ត្រីដែលធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងចង់ស្រាវជ្រាវបន្ថែមទៅលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមនុស្សភាគច្រើនពុំធ្លាប់ឮធ្លាប់ដឹង។ មិនត្រឹមតែប៉ុណ្ណោះ ពួកយើងក៏ចង់ស្វាបស្ទង់នូវចំណេះដឹង និងសមត្ថភាពផ្ទាល់ខ្លួនក្នុងការស្រាវជ្រាវ បន្ទាប់ពីសិក្សាអស់រយៈពេលជិត៤ឆ្នាំ។ យើងខ្ញុំក៏ចង់បន្សល់ទុកនូវស្នាដៃមួយសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយសិក្សាស្វែងយល់និងរៀនសូត្របន្ថែម ក្រោយពីពួកយើងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្រ្តសេដ្ឋកិច្ចក្នុងសាកលវិទ្យាល័យនេះ។

ជាការពិតណាស់ ការសិក្សាស្រាវជ្រាវមិនមែនជារឿងមួយងាយស្រួលដូចអ្វីដែលយើងបានគិតនោះទេ។ ឆ្លងកាត់ការស្រាវជ្រាវនេះ ពួកយើងបាននូវជួបនូវឧបសគ្គជាច្រើនរួមមានការស្វែងរកឯកសារ និងការចុះយកព័ត៌មានផ្ទាល់ពីស្ត្រីដែលប្រកបមុខរបរនេះ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏ពួកយើងមិនរាថយ និងតស៊ូជម្នះរាល់ឧបសគ្គក្នុងការចងក្រងសៀវភៅនេះឡើង។ ម្យ៉ាង ពួកយើងសូមអះអាងផងដែរថា សៀវភៅមួយក្បាលនេះមិនទាន់ល្អឥតខ្ចោះនៅឡើយទេ ពួកយើងនឹងរីករាយស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាគ្រប់ទម្រង់។ ជាចុងក្រោយ ពួកយើងទាំងពីរសូមអរគុណសម្រាប់អ្នកទាំងអស់ដែលកំពុងចំណាយពេលអានសៀវភៅនេះ។

# មាតិកា

**ទំព័រ**


បញ្ជីអក្សរកាត់ ........ v

បញ្ជីតារាង ........ vi

បញ្ជីក្រាហ្វិក ........ vii


## សេចក្តីផ្តើម


១. លំនាំដើម ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣. កម្មវត្ថុនៃការស្រាវជ្រាវ ........ ២

៤. វិសាលភាពនៃការស្រាវជ្រាវ ........ ២

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២

៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១ រំលឹកទ្រឹស្តីពាក់ព័ន្ធ


១.១. និយមន័យនៃស្ត្រី ........ ៥

១.២. ការរួមចំណែករបស់ស្ត្រីក្នុងសង្គមខ្មែរ ........ ៦

    ១.២.១. ស្ត្រី និងជីវភាព ........ ៦

    ១.២.២. ស្ត្រី និងការអប់រំ ........ ៦

    ១.២.៣. ស្ត្រី និងសេដ្ឋកិច្ច ........ ៧

    ១.២.៤. ស្ត្រី និងនយោបាយ ........ ៧

    ១.២.៥. ស្ត្រី និងរបាំងនៃការចូលរួមក្នុងសង្គម ........ ៨

១.៣. អ្វីទៅជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ? ........ ៨

១.៤. លក្ខណៈទូទៅនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ៩

    ១.៤.១. ប្រវត្តិនៃការសិក្សាទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ១០

    ១.៤.២. ការកំណត់និយមន័យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ១០

        ១.៤.២.១. ទស្សនៈតាមបែបប្រពៃណី ........ ១០

១.៤.២.២. ទស្សនៈបែបថ្មី ........ ១១
១.៤.២.៣. ការកំណត់និយមន័យដោយសកម្មភាព ........ ១១
១.៤.៣. ចំណែកថ្នាក់នៃការងារក្រៅប្រព័ន្ធ ........ ១១
១.៤.៣.១. ការងារក្រៅប្រព័ន្ធក្នុងទីផ្សារការងារ ........ ១១
១.៤.៣.២. បរិបទនៃការងារក្រៅប្រព័ន្ធ ........ ១២
១.៤.៤. ចរិតលក្ខណៈនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ១៣
១.៤.៤.១. ស្របច្បាប់ ឬផ្ទុយពីច្បាប់ ........ ១៣
១.៤.៤.២. សាច់ប្រាក់ជាមធ្យោបាយនៃការដោះដូរ ........ ១៤
១.៤.៤.៣. ប្រាក់ខែ ឬប្រាក់កម្រៃដែលគ្មានការចុះបញ្ជី ........ ១៤
១.៤.៤.៤. លក្ខខណ្ឌពលកម្ម ឬការងារ ........ ១៤
១.៤.៥. មូលហេតុនៃកំណើនសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ១៤
១.៤.៥.១. ការស្រូបយកកម្លាំងពលកម្មមានកំណត់ ........ ១៥
១.៤.៥.២. ឧបសគ្គក្នុងការឈានជើងចូលទីផ្សារក្នុងប្រព័ន្ធ ........ ១៥
១.៤.៥.៣. កង្វះការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ........ ១៥
១.៤.៥.៤. ភាពយ៉ាប់យ៉ឺននៃសេដ្ឋកិច្ច ........ ១៥
១.៤.៥.៥.ស្ត្រីភាគច្រើនបម្រើការក្នុងទីផ្សារ ........ ១៦
១.៥. ទំនាក់ទំនងរវាងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ១៧
១.៦. អំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា ........ ១៧
១.៦.១. ឋានៈការងារ និងប្រភេទរបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ១៧
១.៦.២. ប្រភេទមនុស្សធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ១៨
១.៦.៣. ចរិតលក្ខណៈនៃអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ២០
១.៦.៣.១. ការផ្លាស់ទីនៃប្រជាជន ........ ២០
១.៦.៣.២. ការប្រកបការងាររបស់ស្ត្រី ........ ២០
១.៦.៤. បញ្ហាប្រឈមក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ២១
១.៦.៤.១. ក្របខណ្ឌច្បាប់ និងបទបញ្ញត្តិក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ២២
១.៦.៤.២. បញ្ហាទាក់ទងនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ២២
១.៦.៥. សារៈសំខាន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ........ ២៣

## ជំពូកទី២ អំពីអ្នកលក់ដូរតាមដងផ្លូវក្នុងរាជធានីភ្នំពេញ


២.១. ស្ថានភាពនៃអ្នកលក់ដូរតាមដងផ្លូវក្នុងរាជធានីភ្នំពេញ ........ ២៤
២.២. កត្តាជំរុញឱ្យប្រកបរបរតាមដងផ្លូវ ........ ២៧
២.៣. ឥទ្ធិពលនៃការលក់តាមដងផ្លូវ ........ ២៧
២.៤. បញ្ហាប្រឈមផ្សេងៗ ........ ២៨


## ជំពូកទី៣ ការវិភាគ និងពិភាក្សាលើលទ្ធផលស្រាវជ្រាវ


៣.១. ការវិភាគបែបពិពណ៌នា ........ ៣០
៣.១.១. ស្ថានភាពទូទៅនៃស្ត្រីលក់ភេសជ្ជៈតាមរទេះក្នុងរាជធានីភ្នំពេញ ........ ៣០
៣.១.១.១. អាយុ ........ ៣០
៣.១.១.២. រយៈពេលប្រកបមុខរបរ ........ ៣១
៣.១.១.៣. ស្ថានភាពគ្រួសារ ........ ៣២
៣.១.១.៤. ចំនួនអ្នកនៅក្នុងបន្ទុក ........ ៣៣
៣.១.១.៥. កម្រិតវប្បធម៌ ........ ៣៤
៣.១.២. កត្តាជំរុញឱ្យប្រកបមុខរបរលក់ភេសជ្ជៈតាមរទេះ ........ ៣៤
៣.១.៣. បញ្ហាប្រឈមនានាដែលអ្នកលក់តាមរទេះជួបប្រទះ ........ ៣៦
៣.១.៤. ឥទ្ធិពលអវិជ្ជមានចំពោះគ្រួសារ ........ ៣៨
៣.១.៥. ការលើកកម្ពស់ជីវភាពគ្រួសាររបស់ស្ត្រីតាមរយៈប្រាក់ចំណូល ........ ៣៩
៣.១.៥.១. ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃ ........ ៣៩
៣.១.៥.២. ប្រាក់ចំណេញជាមធ្យមប្រចាំថ្ងៃ ........ ៤១
៣.១.៥.៣. ប្រាក់ចំណាយក្នុងគ្រួសារជាមធ្យមប្រចាំថ្ងៃ ........ ៤២
៣.១.៥.៤. ប្រាក់សន្សំជាមធ្យមប្រចាំខែ ........ ៤២
៣.២. ការវិភាគ SWOT ........ ៤៣
៣.២.១. ចំណុចខ្លាំង ........ ៤៣
៣.២.២. ចំណុចខ្សោយ ........ ៤៣
៣.២.៣. ឱកាស ........ ៤៤
៣.២.៤. ការគំរាមកំហែង ........ ៤៤

## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ........................................................................ ៩៥
២. អនុសាសន៍ ........................................................................ ៩៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ILO | International Labor Organization | អង្គការពលកម្មអន្តរជាតិ |
| WB | World Bank | ធនាគារពិភពលោក |

# បញ្ជីតារាង

**ទំព័រ**


តារាង ១៖ ផ្នែកនៃទីផ្សារការងារ ............................................................................................ ១២

តារាង ២៖ រចនាសម្ព័ន្ធនៃចំណាត់ថ្នាក់ការងារក្រៅប្រព័ន្ធ .................................................................... ១២

តារាង ៣៖ ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃនៃស្ត្រីលក់ភេសជ្ជៈតាមរទេះ ................................. ៤០

តារាង ៤៖ ប្រាក់ចំណេញជាមធ្យមប្រចាំថ្ងៃនៃស្ត្រីលក់ភេសជ្ជៈតាមរទេះ ............................... ៤១

តារាង ៥៖ ប្រាក់ចំណាយក្នុងគ្រួសារជាមធ្យមប្រចាំថ្ងៃនៃស្ត្រីលក់ភេសជ្ជៈតាមរទេះ ............... ៤២

តារាង ៦៖ ប្រាក់សន្សំជាមធ្យមប្រចាំខែនៃស្ត្រីលក់ភេសជ្ជៈតាមរទេះ ..................................... ៤៣

# បញ្ជីក្រាហ្វិក

**ទំព័រ**

ក្រាហ្វិក ១៖ អាយុ....................................................................................................................................៣១
ក្រាហ្វិក ២៖ រយៈពេលប្រកបមុខរបរ ........................................................................................................ ៣២
ក្រាហ្វិក ៣៖ ស្ថានភាពគ្រួសារ ................................................................................................................... ៣២
ក្រាហ្វិក ៤៖ ចំនួនអ្នកនៅក្នុងបន្ទុក ............................................................................................................៣៣
ក្រាហ្វិក ៥៖ កម្រិតវប្បធម៌........................................................................................................................៣៤
ក្រាហ្វិក ៦៖ កត្តាជំរុញឱ្យគាត់ប្រកបមុខរបរលក់ភេសជ្ជៈតាមរទេះ .......................................................៣៥
ក្រាហ្វិក ៧៖ ប្រភពនៃដើមទុនសម្រាប់ចាប់ផ្តើមអាជីវកម្ម...................................................................៣៦
ក្រាហ្វិក ៨៖ បញ្ហាប្រឈមពេលចាប់ផ្តើមអាជីវកម្ម ..........................................................................៣៧
ក្រាហ្វិក ៩៖ បញ្ហាប្រឈមកំឡុងពេលប្រកបអាជីវកម្ម.........................................................................៣៨
ក្រាហ្វិក ១០៖ ឥទ្ធិពលអវិជ្ជមានចំពោះគ្រួសារ ......................................................................................៣៩
ក្រាហ្វិក ១១៖ ប្រាក់ចំណូលជាមធ្យមក្នុងមួយថ្ងៃ ................................................................................ ៤០
ក្រាហ្វិក ១២៖ ប្រាក់ចំណេញជាមធ្យមក្នុងមួយថ្ងៃ ............................................................................... ៤១

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

សេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានគេហៅឈ្មោះខុសៗគ្នាជាច្រើន ដូចជា សហគមន៍អ្នកក្រ សហគ្រាសគ្រួសារ សកម្មភាពមិនបានគ្រោងទុក សហគ្រាសដែលមានម្ចាស់តែម្នាក់ជាដើម ដោយយោងទៅតាមទីកន្លែង និងការយល់ឃើញប្លែកៗពីគ្នា។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ មានមួយភាគបីនៃការងារក្រៅពីការងារក្នុងវិស័យកសិកម្ម និងបានស្រូបទាញយកកម្លាំងពលកម្មជាច្រើន។ ជាក់ស្តែង ៤៨%នៃប្រជាជននៅប៉ែកអាហ្វ្រិកខាងជើងប្រកបរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ រីឯនៅអាមេរិចឡាទីន (Latin America) មានចំនួន ៥១% ចំណែកនៅប៉ែកអាស៊ី ប្រជាជនដែលប្រកបរបរនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះមានរហូតដល់៦៥% ។[1] លើសពីនេះទៅទៀត នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ អ្នកដែលជាប់ពាក់ព័ន្ធក្នុងវិស័យនេះភាគច្រើនជាស្ត្រី ដោយពួកគាត់ភាគច្រើនប្រកបរបរតាមដងផ្លូវ ឬក៏លក់ទំនិញតាមរទេះរុញ អ្នកធ្វើការតាមគេហដ្ឋាន អ្នកលក់ផលិតផលដែលផលិតដោយខ្លួនឯង ឬអ្នកធ្វើការរោងចក្រជាដើម។[2]

## ១. លំនាំបញ្ហា

ប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅលើពិភពលោក កំពុងតែយកចិត្តទុកដាក់ខ្លាំងលើស្ត្រី ជាពិសេសតួនាទីស្ត្រីនៅក្នុងការជំរុញកំណើនសេដ្ឋកិច្ច។ ប៉ុន្តែបើតាមការសង្កេតជាក់ស្តែង បានបង្ហាញឱ្យឃើញថាស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ច្រើនតែធ្វើការនៅក្នុងវិស័យការងារដែលពុំសូវទទួលបានប្រាក់ចំណូលខ្ពស់ តួយ៉ាងការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលការងារក្នុងវិស័យនេះ បានរួមចំណែកនៅក្នុងផលិតផលក្នុងស្រុកសរុបតែបន្តិចបន្តួចប៉ុណ្ណោះ ប៉ុន្តែបែរជាជួយលើកកម្ពស់ជីវភាពគ្រួសាររបស់ពួកគាត់បានមួយកម្រិត។

ជាក់ស្តែងនៅប្រទេសកម្ពុជា កាលពីដើមឡើយ គេតែងតែគិតថា ស្ត្រីមិនអាចផ្តល់ប្រយោជន៍ ឬមិនអាចរកស៊ីចិញ្ចឹមជីវិតបានទេ ព្រោះស្ត្រីគឺជាភេទទន់ខ្សោយមានតួនាទីនៅផ្ទះមើលថែទាំកូន និងធ្វើការងារផ្ទះប៉ុណ្ណោះ ហើយត្រូវពឹងផ្អែកទាំងស្រុងទៅលើស្វាមីដែលជាអ្នកផ្គត់ផ្គង់ជីវភាពគ្រួសារទាំងមូល។ ប៉ុន្តែនាពេលបច្ចុប្បន្ន តាមការសង្កេតជាក់ស្តែងបង្ហាញថា ចំនួនស្ត្រីដែលកំពុងធ្វើការនៅក្នុងស្ថាប័ន ឬក្រុមហ៊ុននានាមានការកើនឡើង ជាពិសេស ការប្រកប

[1] International Labour Organization, *Women and Men in the Informal Sector,* (2002)។

[2] Women in informal employment, globalizing and organizing, *Women in The Informal Economy*។

ការងារដែលស្ថិតនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធដូចជា ការលក់ដូរតាមដងផ្លូវ និងការធ្វើការតាមផ្ទះ ដែលពួកគាត់អាចរកចំណូលបានដើម្បីរួមចំណែកផ្គត់ផ្គង់ជីវភាពគ្រួសាររបស់គាត់បាន។

## ២. ចំណោទបញ្ហា

ខណៈពេលដែលស្ត្រីបានបោះបង់នូវទម្លាប់ពឹងផ្អែកទាំងស្រុងទៅលើស្វាមី រួចចេញទៅប្រកបមុខរបរតូចតាចក្នុងវិស័យក្រៅប្រព័ន្ធដើម្បីរួមចំណែកស្វែងរកប្រាក់ចំណូលដល់គ្រួសារ តើស្ត្រីលើកកម្ពស់ជីវភាពគ្រួសារតាមរយៈសេដ្ឋកិច្ចក្រៅប្រព័ន្ធយ៉ាងដូចម្ដេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានគោលដៅ៖

- ស្វែងយល់ពីមូលហេតុដែលស្ត្រីសម្រេចចិត្តធ្វើជាអ្នកលក់ភេសជ្ជៈតាមរទេះ
- ស្វែងយល់ពីផលប្រយោជន៍ដែលស្ត្រីទទួលបានពីមុខរបរនេះ
- ស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ស្ត្រីក្នុងមុខរបរនេះ
- ស្វែងយល់ពីការគំរាមកំហែង និងផលលំបាករបស់ស្ត្រីក្នុងមុខរបរនេះ
- បង្ហាញការរួមចំណែករបស់ស្ត្រីក្នុងការលើកកម្ពស់ជីវភាពគ្រួសារតាមរយៈប្រាក់ចំណូល និងសន្សំរបស់ពួកគាត់។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងប្រធានបទនេះ យើងខ្ញុំនឹងសិក្សាទៅលើប្រាក់ចំណូលរបស់ស្ត្រីដែលកំពុងប្រកបមុខរបរក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងរាជធានីភ្នំពេញនាឆ្នាំ២០១៧ ព្រមទាំងចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែងផ្សេងៗ ដោយផ្តោតសំខាន់ទៅលើតែស្ត្រីដែលលក់ភេសជ្ជៈតាមរទេះ តាមរយៈទិន្នន័យចម្បងដែលទទួលបានពីកម្រងសំណួរទាំងស្រុង។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះ គឺពឹងផ្អែកទាំងស្រុងទៅលើទិន្នន័យចម្បង ដោយយើងខ្ញុំនឹងធ្វើការសម្ភាសន៍ជាមួយស្ត្រីដែលប្រកបមុខរបរលក់ភេសជ្ជៈតាមរទេះ ដើម្បីទទួលយកព័ត៌មាន និងទិន្នន័យដែលពួកយើងចង់បាន ដោយប្រើប្រាស់នូវកម្រងសំណួរដែលពួកយើងបានរៀបចំ។ ទិន្នន័យនេះនឹងផ្តោតសំខាន់ទៅលើប្រាក់ចំណូល ចំណាយ សន្សំ របស់ពួកគាត់ថាតើប្រាក់ចំណូលរបស់គាត់អាចរួមចំណែកក្នុងគ្រួសារបានឬយ៉ាងណា។ ទិន្នន័យដែលត្រូវយកមកវិភាគ ពឹងផ្អែកទាំងស្រុងលើទិន្នន័យក្នុងកម្រងសំណួរ។

ដោយសារតែពេលវេលាដែលត្រូវធ្វើការស្រាវជ្រាវមានរយៈពេលខ្លី គួបផ្សំនឹងធនធានថវិកាដែលចំណាយមានកម្រិត យើងសម្រេចជ្រើសរើសគំរូតាង (អ្នកត្រូវបានសម្ភាសន៍ដែលជាស្ត្រីលក់ភេសជ្ជៈតាមរទេះលើដងផ្លូវក្នុងរាជធានីភ្នំពេញ) ចំនួនត្រឹមតែ ៤៨ ដែលគំរូតាងទាំងនោះត្រូវបានជ្រើសរើសដោយចៃដន្យពីក្នុងចំណោមស្ត្រីលក់ភេសជ្ជៈតាមរទេះទាំងអស់នៅក្នុងខណ្ឌទាំង១២នៃរាជធានីភ្នំពេញ។ គំរូតាងចំនួន ៤ ត្រូវបានជ្រើសរើសពីក្នុងខណ្ឌនីមួយៗដើម្បីរក្សាឱ្យបាននូវកម្រិតជឿជាក់នៃទិន្នន័យដែលត្រូវយកមកវិភាគ។ ការប្រមូលទិន្នន័យគិតចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៧។

ក្រោយពីទទួលបានទិន្នន័យ ពួកយើងធ្វើការបញ្ចូលទិន្នន័យទៅក្នុងកម្មវិធី SPSS ដើម្បីធ្វើការវិភាគទៅតាមអ្វីដែលយើងចង់បាន។ ទិន្នន័យទាំងអស់ដែលទទួលបានពីការវិភាគក៏ត្រូវបានប្រើប្រាស់ដើម្បីជាមធ្យោបាយក្នុងការវិភាគ SWOT ផងដែរ។

ក្រៅពីទិន្នន័យចម្បង ពួកយើងធ្វើការស្រាវជ្រាវផ្សេងៗទៀត ដូចជា ឯកសារ របាយការណ៍ចេញផ្សាយដោយអង្គការ ឬស្ថាប័នមួយចំនួនដូចជា អង្គការពលកម្មអន្តរជាតិនៅកម្ពុជា (ILO) និង ការស្រាវជ្រាវឯកសារតាមរយៈគេហទំព័រ (Website) ដើម្បីទទួលបានទិន្នន័យដែលមានស្រាប់មួយចំនួនទៅតាមតម្រូវការ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ បានផ្តល់នូវចំណេះដឹងទាក់ទងនឹងស្ត្រីដែលបានរួមចំណែកលើកកម្ពស់ជីវភាពគ្រួសាររបស់ខ្លួនតាមរយៈការប្រកបរបរក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ (លក់ភេសជ្ជៈតាមរទេះ) ក៏ដូចជាបង្ហាញឱ្យឃើញពីផលលំបាកដែលពួកគាត់ជួបប្រទះក្នុងពេលចាប់ផ្តើម និងកំឡុងពេលប្រកបមុខរបរនេះ។ ក្រោយពីបញ្ចប់ការស្រាវជ្រាវនេះ យើងសង្ឃឹមយ៉ាងមុតមាំថា សមត្ថកិច្ចជាប់ពាក់ព័ន្ធទាំងអស់នឹងមានវិធានការក្នុងការលុបបំបាត់ ឬកាត់បន្ថយ នូវបញ្ហានានាដែលពួកគាត់ជួបប្រទះ និងជួយការពារជ្រោមជ្រែងពួកគាត់ឱ្យបានល្អប្រសើរ។ ជាងនេះទៅទៀត ការសិក្សានេះ នឹងក្លាយជាទុនមួយសម្រាប់អ្នកសិក្សាដែលមានចំណាប់អារម្មណ៍ ចង់យល់ ចង់ដឹងអំពីការចូលរួមរបស់ស្ត្រីក្នុងការលើកស្ទួយជីវភាពគ្រួសារតាមរយៈសេដ្ឋកិច្ចក្រៅប្រព័ន្ធ ម៉្យាងវាក៏អាចជាស្ពានចម្លងឱ្យអ្នកស្រាវជ្រាវដទៃទៀតធ្វើការសិក្សាលើបញ្ហានេះបន្ថែមទៀតទៅតាមការចង់បាន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះចែកចេញជាបីជំពូកដែលមានដូចខាងក្រោម៖

- ជំពូកទី១ រំលឹកទ្រឹស្តីពាក់ព័ន្ធ
- ជំពូកទី២ អំពីស្ត្រីលក់ដូរតាមដងផ្លូវក្នុងរាជធានីភ្នំពេញ
- ជំពូកទី៣ ការវិភាគ និងពិភាក្សាលើលទ្ធផលស្រាវជ្រាវ ។

# ជំពូកទី១

# រំលឹកទ្រឹស្តីពាក់ព័ន្ធ

# ជំពូកទី១
# រំលឹកទ្រឹស្តីពាក់ព័ន្ធ

យោងទៅតាមប្រធានបទ "**ស្ត្រីលើកកម្ពស់ជីវភាពគ្រួសារតាមរយៈសេដ្ឋកិច្ចក្រៅប្រព័ន្ធ**" យើងនឹងសិក្សាលើពាក្យគន្លឹះពីរ ។ ពាក្យទីមួយគឺ **ស្ត្រី** និងមួយទៀតគឺ **សេដ្ឋកិច្ចក្រៅប្រព័ន្ធ**។ ជាការពិតណាស់អ្នកសិក្សាជាច្រើនប្រាកដជាយល់នូវពាក្យថា **ស្ត្រី** ប៉ុន្តែមនុស្សមួយចំនួនច្បាស់ជាចង់ដឹងថា អ្វីទៅជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ? តើវាសំដៅលើអ្វី? ដោយសារតែបច្ចុប្បន្នយើងសង្កេតឃើញថាអ្នកសិក្សាភាគច្រើនយកចិត្តទុកដាក់ និងស្រាវជ្រាវពាក់ព័ន្ធតែសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដោយពុំសូវចាប់អារម្មណ៍ទៅលើសេដ្ឋកិច្ចក្នុងប្រព័ន្ធប៉ុន្មានទេ ដែលជាហេតុដែលធ្វើឱ្យសេដ្ឋកិច្ចក្រៅប្រព័ន្ធមិនសូវជាមានអ្នកស្គាល់ ក៏ដូចជាផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅឡើយ។ ដើម្បីស្រាយនូវចម្ងល់ទាំងនេះដល់មិត្តៗ និស្សិត សាស្ត្រាចារ្យ ក៏ដូចជាអ្នកសិក្សាទាំងអស់ នៅក្នុងជំពូកនេះ យើងនឹងលើកនិយមន័យនៃពាក្យគន្លឹះទាំងនោះមកពន្យល់ ដើម្បីទម្លាយនូវរាល់មន្ទិលសង្ស័យ។

## ១.១. និយមន័យស្ត្រី

យោងតាមវចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ ជួន ណាត ស្ត្រី គឺជាមនុស្សជាតិដែលមានភេទទីទៃពីប្រុស។

លោក Meyerowitz បានពន្យល់ថា ស្ត្រីត្រូវបានចាត់ទុកជា អ្នកដែលថែរក្សាក្នុងផ្ទះ ហើយមានទំនួលខុសត្រូវខ្ពស់ក្នុងការថែរក្សាផ្ទះសម្បែង និងថែទាំបុត្រធីតា។[3]

យោងតាមការស្រាវជ្រាវរបស់ Courtney និង Lockeretz បានបង្ហាញឱ្យឃើញថា ទីមួយ ស្ត្រីគឺជាមនុស្សដែលមានតួនាទីរស់នៅផ្ទះជាមួយក្រុមគ្រួសារ។ កាតព្វកិច្ចជាម្តាយ និងការមើលថែរក្សាផ្ទះសម្បែង និងមើលការខុសត្រូវកូននិងបម្រើស្វាមី គឺជាគោលដៅសំខាន់បំផុតរបស់ស្ត្រីទាំងឡាយ ព្រមទាំងជាឱកាសដ៏មានតម្លៃបំផុត។ ទីពីរ ស្ត្រីជាមនុស្សដែលមិនអាចធ្វើការសម្រេចចិត្តលើកិច្ចការធំដុំ។ ជាក់ស្តែង ការសម្រេចចិត្តរបស់ស្ត្រីរមែងតែងតែមានការការជ្រោមជ្រែងពីបុរសនៅខាងក្រោយខ្នង។ ចុងក្រោយ ស្ត្រីជាប្រភេទមនុស្សដែលមិនឯករាជ្យ និងត្រូវការការការពារនិងទទួលយកពីបុរសខ្លាំងបំផុត។

[3] Meyerowitz, J. *Not June Cleaver, Women and Gender in Postwar America*. (Philadelphia: Temple University Press,1994)។

យោងទៅតាមលោក Hakim ស្ត្រី គឺជាភេទមួយដែលទទួលបានការងារក្នុងចំណែកតូចជាងបុរស និងធ្វើការក្រៅម៉ោងនៅក្នុងសហគ្រាសតូចតាចជាដើម។ ម៉្យាងវិញទៀត ទោះបីជា ស្ត្រីបានចូលរួមក្នុងការងារដែលទទួលបានកម្រៃក៏ដោយ ក៏ពួកគាត់ទទួលបានប្រាក់កម្រៃទាបជាងបុរស និងទទួលការងារដែលគ្មានជំនាញជាដើម។[4]

## ១.២. ស្ថានភាពទូទៅនៃស្ត្រីក្នុងសង្គមខ្មែរ

### ១.២.១. ស្ត្រី និងជីវភាពគ្រួសារ

នៅក្នុងឆ្នាំ ២០០៣ ប្រហែល៨៤%នៃប្រជាជនកម្ពុជារស់នៅតំបន់ជនបទ។ ៩០%នៃប្រជាជនទាំងនោះរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ ជាពិសេសភាគច្រើននៃប្រជាពលរដ្ឋទាំងនោះ គឺជាស្ត្រី។ នៅសម័យដើមភាពក្រីក្រក្នុងគ្រួសារបណ្តាលឱ្យមនុស្សទ័លប្រាជ្ញា និងនាំឱ្យមនុស្សធ្វើសកម្មភាពអសកម្មប្រាសចាកការពិចារណានៃច្បាប់ ដែលជនរងគ្រោះភាគច្រើនជាស្ត្រី។ ឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃជាច្រើនទសវត្សមក ស្ត្រីមួយចំនួនក្នុងសង្គមគ្រួសារខ្មែរបាត់បង់នូវសេក្តីថ្លៃថ្នូរភាពរាបសារ និងភាពទន់ភ្លន់សមជានារីខ្មែរ។ ដោយសារតែភាពក្រីក្រពេលខ្លះស្ត្រីទាំងនោះបានបង្ខំចិត្តប្រព្រឹត្តអំពើប្រាសចាកពីអំពើមនុស្សធម៌។ ពួកគេគិតថាការប្រកបរបរទាំងនេះអាចជួយសម្រួលដល់ជីវភាពគ្រួសាររបស់គេបានមួយកម្រិត ប៉ុន្តែមិនបានគិតដល់ថា ការងារទាំងនោះនឹងនាំគ្រោះថ្នាក់ដល់ជីវិតក្នុងពេលដ៏ខ្លីឡើយ។ ប៉ុន្តែប្រសិនបើក្រឡេកមកមើល ស្ត្រីនាពេលបច្ចុប្បន្នវិញ ភាគច្រើននៃស្ត្រីមានសមត្ថភាពអាចរកចំណូលផ្គត់ផ្គង់គ្រួសារបានមួយចំណែក បើទោះបីជាការងារទាំងនោះមិនបានផ្តល់កិត្តិយស ដល់ពួកគាត់ក៏ដោយ ប៉ុន្តែការងារទាំងនោះ គឺជាការងារសុចរិត។[5]

### ១.២.២. ស្ត្រី និងការអប់រំ

នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន យើងសង្កេតឃើញថា ការអប់រំ និងការបណ្តុះបណ្តាល គឺជាកត្តាដ៏ចម្បងមួយសម្រាប់ឆ្ពោះទៅរកការអភិវឌ្ឍន៍នូវធនធានមនុស្ស ព្រមទាំងសង្គមទាំងមូល។ ការអប់រំ និងការបណ្តុះបណ្តាលគឺជាផ្នែកមួយដែលពុំអាចខ្វះបានសម្រាប់មនុស្សគ្រប់រូប ជាពិសេសចំពោះស្ត្រី តាំងពីក្នុងក្រុមគ្រួសាររហូតដល់ក្នុងសង្គមទាំងមូល។ ជាក់ស្តែង នៅក្នុងសង្គម

[4] Hakim, *Occupational Segregation*, 1979។

[5] No name, *Gender in poverty Reduction, (NGO Sector and issues Papers on Poverty Reduction and development in Cambodia,2003), 37*។

ខ្មែរបច្ចុប្បន្ន ស្ត្រីត្រូវបានផ្តល់សិទ្ធិឱ្យស្មើនឹងបុរសក្នុងការទទួលយកការអប់រំយ៉ាងពេញលេញ តាំងពីកម្រិតបឋមដល់កម្រិតឧត្តម។

**១.២.៣. ស្ត្រី និងសេដ្ឋកិច្ច**

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ស្ត្រីគឺជាអ្នកដើរតួយ៉ាងសំខាន់ក្នុងសកម្មភាពសេដ្ឋកិច្ច ហើយត្រូវបានទទួលស្គាល់ថាជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ។ ជាក់ស្តែង រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរបស់ស្ត្រីតាមរយៈការអនុវត្តន៍ផែនការយុទ្ធសាស្ត្រនារីរតនៈ ឬហៅថា "ស្ត្រីគឺជាត្បូងដ៏មានតម្លៃ" ដើម្បីទទួលបានការផ្តល់ឱ្យស្ត្រីកម្ពុជានូវតម្លៃ និងក្តីសង្ឃឹមក្នុងជីវិត ព្រមទាំងការលើកកម្ពស់ការបញ្ជ្រាបយេនឌ័រ។[6]

ទន្ទឹមនឹងនេះ ស្ត្រីដើរតួយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ជីវភាពគ្រួសារ ដែលជាមូលហេតុដែលនាំឱ្យមានការកើនឡើងនូវផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធរបស់ស្ត្រីគ្រប់ទីកន្លែងទូទាំងប្រទេស។ ស្ត្រីខ្មែរភាគច្រើនរមែងតែងតែខិតខំប្រកបរបររបន្ទាប់បន្សំដើម្បីបន្ថែមលើប្រាក់បៀវត្សរ៍របស់ស្វាមី ឬជួយស្វាមីដែលគ្មានការងារធ្វើក្នុងការចិញ្ចឹមជីវិតបុត្រធីតា ទោះបីជាពួកគាត់មិនសូវមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ឬមិនមានសមត្ថភាព និងវិជ្ជាជីវៈ ក៏ពួកគាត់មិនរារែកក្នុងការស្វះស្វែងរកការងារតាមគ្រប់មធ្យោបាយដើម្បីជួយទ្រទ្រង់ជីវភាពគ្រួសារ។

**១.២.៤. ស្ត្រី និងនយោបាយ**

បើនិយាយពីរឿងនយោបាយ ប្រជាពលរដ្ឋគ្រប់រូបតែងតែមានភាពភ័យខ្លាចរអារមិនចង់អើពើ។ ពួកគេតែងយល់ថានយោបាយគឺជាការភូតភរ ការបោកប្រាស់ ការកេងប្រវ័ញ្ច អំពើពុករលួយ ការកៀបសង្កត់ ហើយពោរពេញទៅដោយគ្រោះថ្នាក់ ដែលភាគច្រើនកើតមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ចំពោះស្ត្រី ពួកគាត់គឺជាប្រភេទមនុស្សដែលចូលចិត្តនូវភាពស្ងប់ស្ងាត់ សុខសន្តិភាព មិនចូលចិត្តសង្គ្រាម ដែលសុទ្ធតែជាមូលហេតុដែលអាចនាំឱ្យបាត់បង់ក្រុមគ្រួសារ ប្តី កូនចៅ ម្ល៉ោះហើយ ពួកគាត់តែងតែមិនចង់ដឹង មិនចង់ឮរឿងដែលពាក់ព័ន្ធនឹងនយោបាយឡើយ។

[6] វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ, *ស្ត្រី និងបុរសនៅកម្ពុជា* (ភ្នំពេញ៖ ២០១១)។

### ១.២.៥. ស្ត្រី និងរបាំងនៃការចូលរួមក្នុងសង្គម

កាងារទាំងអស់ ទាំងផ្នែកវប្បធម៌ នយោបាយ សេដ្ឋកិច្ច មនុស្សសាស្ត្រ រួមទាំងមុខរបរដទៃទៀត ជាច្រើនសុទ្ធតែត្រូវការស្ត្រីចូលរួម បើគ្មានស្ត្រីចូលរួមនោះទេ ការងារទាំងនោះពិតជាមិនអាចសម្រេចបានជោគជ័យឡើយ។ ប៉ុន្តែសម្រាប់សង្គមបច្ចុប្បន្ន យើងឃើញថា ចំនួនស្ត្រីចូលរួមនៅក្នុងការងារសង្គមមានតិចតួចបំផុត ជាពិសេសនៅក្នុងការងារដែលត្រូវសម្រេចចិត្តខ្ពស់។

ជារួម ស្ត្រីទាំងអស់មានសិទ្ធិក្នុងការថែទាំសុខភាព ការសិក្សាអប់រំ និងបណ្តុះបណ្តាលជំនាញ។ ពួកគាត់ត្រូវបានផ្តល់សិទ្ធិឱ្យស្មើភាព លើការបែងចែកធនធានសេដ្ឋកិច្ច ស្មើភាពលើឱកាសចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច និងស្មើភាពលើការការពារតាមផ្លូវច្បាប់ ដែលនាំឱ្យស្ត្រីអាចចៀសវាងបានពីអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរ។ ម្យ៉ាងវិញទៀត ស្ត្រីក៏មានសិទ្ធិស្មើភាពក្នុងការចូលរួមនៅគ្រប់កម្រិតទាំងអស់នៃការងារអភិបាលកិច្ចល្អ។

## ១.៣. អ្វីទៅជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ?

ពាក្យផ្សេងៗគ្នាជាច្រើនត្រូវបានប្រើប្រាស់ដើម្បីសំដៅទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ ផ្អែកលើអ្នកប្រាជ្ញផ្សេងៗពីគ្នា។ ពាក្យសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបានគេហៅថា សេដ្ឋកិច្ចមិនទៀងទាត់ (Irregular economy) [7] សេដ្ឋកិច្ចក្នុងរូងភ្នំ (Subterranean economy) សេដ្ឋកិច្ចក្រោមដី (Underground economy) សេដ្ឋកិច្ចខ្មៅ (Black economy) សេដ្ឋកិច្ចស្រមោល (Shadow economy) និងសេដ្ឋកិច្ចក្រៅផ្លូវការ (Informal economy)។[8]

លោក Gutmann ប្រើប្រាស់ពាក្យសេដ្ឋកិច្ចក្នុងរូងភ្នំ (Subterranean economy) សំដៅទៅលើប្រតិបត្តិការទាំងអស់ដែលគេចវេសន៍ពីការបង់ពន្ធ។[9]

លោក Feige បង្ហាញថា សេដ្ឋកិច្ចក្រៅប្រព័ន្ធជាសេដ្ឋកិច្ចលាក់បាំង (Hidden economy) ដោយសារតែវាគេចខ្លួនទាំងស្រុងពីការវាស់វែងរបស់សង្គម។[10]

លោក Tanzi (1982) ហៅសេដ្ឋកិច្ចក្រៅប្រព័ន្ធថាជាសេដ្ឋកិច្ចក្រោមដី (Underground economy) ព្រោះផលិតផលជាតិសរុបមិនត្រូវបានវាស់វែងដោយស្ថិតិផ្លូវការទាំងស្រុង។

---

[7] Ferman, P., & Ferman, L., "The structural Underpinning of irregular economy", *Poverty and Human Resources Abstracts*, 8(1973): 3-17។

[8] Losby, J., Elsse, J., Kingslow, M., Edgcomb, E., &Malm, E., *Informal Economy Literature Review,* (2002) ។

[9] Gutmann, P., "The subterranean economy", *Financial Analyst Journal*, 33(1977): 26-27។

[10] Feige, S., *Urban Labor Market Modelling and the Informal Sector*, (1989)។

យោងទៅតាមអង្គការពលកម្មអន្តរជាតិ សេដ្ឋកិច្ចក្រៅប្រព័ន្ធ ជាអង្គភាពដែលមានទំហំតូចតាច ឬជាសហគ្រាសតាមបែបគ្រួសារដែលផលិតឬចែកចាយទំនិញ និងសេវាកម្ម ដែលក្នុងនោះអ្នកផលិត គឺជាបុគ្គលឯករាជ្យ ស្វ័យគ្រប់គ្រងដែលមានអ្នកខ្លះបានជួលនិយោជិត ឬកូនជាងពីរបីនាក់ ឬបានប្រើប្រាស់កម្លាំងពលកម្មរបស់សមាជិកក្នុងបន្ទុកគ្រួសារផ្ទាល់សម្រាប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ អង្គភាពទាំងនេះមានដំណើរការអាជីវកម្មដោយការចំណាយដើមទុនតិចតួចបំផុត ព្រមជាមួយនឹងការប្រើប្រាស់នូវគ្រឿងបរិក្ខារបច្ចេកវិទ្យា និងជំនាញទាបក្នុងដំណើរការដែលជាហេតុធ្វើឱ្យទទួលបានផលិតភាពទាប។ ជាទូទៅ សេដ្ឋកិច្ចក្រៅប្រព័ន្ធសំដៅដល់សកម្មភាពទាំងឡាយណាដែលគ្មានរូបភាពជាក្រុមហ៊ុន និងគ្មានអាសយដ្ឋានទំនាក់ទំនងច្បាស់លាស់។ សេដ្ឋកិច្ចក្រៅប្រព័ន្ធគឺជាសកម្មភាពទាំងឡាយណា ដែលបុគ្គលនោះធ្វើការងារដោយខ្លួនឯង ជាធម្មតាគ្មានតួរលេខនៅក្នុងស្ថិតិរបស់ជាតិឡើយ ជាពិសេសវាក៏ជាសកម្មភាពដែលប្រើកម្លាំងពលកម្មច្រើនជាងប្រើម៉ាស៊ីន និងផ្លាស់ប្តូរកម្មករជាញឹកញាប់។ លើសពីនេះទៅទៀត សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសកម្មភាពទាំងឡាយណា ដែលប្រើប្រាស់កម្លាំងមនុស្ស ឬសត្វពាហនៈ និងជាសកម្មភាពដែលកើតឡើងនៅក្នុងស្ថានភាពគ្មានរចនាសម្ព័ន្ធត្រឹមត្រូវ គ្មានអាជ្ញាបណ្ណ និងគ្មានការបង់ពន្ធ។ ម៉្យាងការងារទាំងនោះមិនបានដំណើរការក្នុងទីផ្សារត្រឹមត្រូវ គ្មានការពាក់ព័ន្ធនឹងស្ថាប័នហិរញ្ញវត្ថុ ស្ថាប័នអប់រំបណ្តុះបណ្តាលផ្លូវការជាដើម។ ជាពិសេសទៅទៀត វាគ្មានការរៀបចំត្រឹមត្រូវ និងគ្មានការគាំទ្រនិងគ្រប់គ្រងពីរដ្ឋាភិបាល ហើយរមែងដំណើរការនៅក្រៅក្របខណ្ឌច្បាប់ ដែលជាហេតុធ្វើឱ្យអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធពុំទទួលបានរបបសន្តិសុខសង្គម និងការធានារ៉ាប់រងផ្សេងៗ។[11]

## ១.៤. លក្ខណៈទូទៅនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

នៅក្នុងចំណុចនេះ យើងនឹងបង្ហាញអំពីប្រវត្តិនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងបង្ហាញនូវផ្នែកពីរសំខាន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបែងចែកការងារនិងសកម្មភាពនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងចរិតលក្ខណៈចម្បងៗទាំងបួននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ចុងក្រោយ សកម្មភាពការងារដែលមិនត្រូវបានរួមបញ្ចូលក្នុងនិយមន័យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនឹងត្រូវបានបកស្រាយ។

[11] Cooperation Committee for Cambodia, *Selling to Survive: Market Vendors in Kampong Cham Town Making their Living in the Informal Economy, (CCC: 2008)* ។

### ១.៤.១. ប្រវត្តិនៃការសិក្សានៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ពាក្យ សេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវបានបង្កើតឡើងនៅក្នុងការសិក្សារបស់អង្គការពលកម្មអន្តរជាតិ (ILO) លើទីផ្សារការងាររបស់ប្រទេសកាណា។ បន្ទាប់មក វាត្រូវបានប្រើនៅក្នុងរបាយការណ៍របស់ILO ស្តីអំពីលក្ខខណ្ឌនៃទីផ្សារពលកម្មក្នុងប្រទេសនៃទ្វីបអាហ្វ្រិក និងត្រូវបានប្រើប្រាស់ដោយធនាគារពិភពលោក ក្នុងការសិក្សាពីនគរូបនីយកម្មនិងភាពក្រីក្រក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ពាក្យនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ជាមធ្យោបាយក្នុងការពិពណ៌នាអំពីរចនាសម្ព័ន្ធនៃសេដ្ឋកិច្ចពីរ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ សេដ្ឋកិច្ចប្រភេទនេះរួមបញ្ចូលនូវ សេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅផ្លូវការឬក្រៅប្រព័ន្ធ ដែលប្រតិបត្តិការកើតឡើងក្រៅប្រព័ន្ធប្រពៃណី ហើយផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមយ៉ាងច្រើន។ វាត្រូវបានវិវត្តន៍ដោយគ្របដណ្តប់ទៅលើប្រភេទជាច្រើននៃប្រតិបត្តិការជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ទាំងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍។

### ១.៤.២. ការកំណត់និយមន័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ក្នុងទសវត្សឆ្នាំ១៩៧០ ពាក្យ វិស័យបែបប្រពៃណី ឬវិស័យក្រៅប្រព័ន្ធ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជំនួសឱ្យពាក្យ សេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយសំដៅទៅលើសកម្មភាពទាំងឡាយដែលគ្មានការទទួលស្គាល់ កត់ត្រា ការពារ ឬគ្រប់គ្រងដោយអាជ្ញាធរមានសមត្ថកិច្ច។ ទស្សនៈសំខាន់ៗ ចំនួនពីរបានផ្តល់និយមន័យនៃពាក្យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

#### ១.៤.២.១. ទស្សនៈតាមបែបប្រពៃណី

សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសេដ្ឋកិច្ចបែបប្រពៃណី ដែលនឹងលិចបាត់នៅពេលដែលមានកំណើនឧស្សាហូបនីយកម្ម។ ទន្ទឹមនឹងនេះ សេដ្ឋកិច្ចក្រៅប្រព័ន្ធ គ្រាន់តែជាកន្លែងបណ្តោះអាសន្ន សម្រាប់ភាពលើសនៃកម្លាំងពលកម្មប៉ុណ្ណោះ នៅពេលដែលសេដ្ឋកិច្ចក្នុងប្រព័ន្ធពុំដំណើរការ។ ការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានដូចជា អ្នកលក់ដូរតាមដងផ្លូវ និងផលិតករក្នុងទ្រង់ទ្រាយតូច។ លើសពីនេះទៀត សហគ្រិនក្នុងវិស័យនេះ ជាអ្នកស្ថិតនៅក្រៅច្បាប់ មិនបានចុះបញ្ជីសហគ្រាស មិនមានការគ្រប់គ្រង និងមិនបង់ពន្ធជូនរដ្ឋ។ ការងារទាំងអស់នេះ គ្រាន់តែជាសកម្មភាពប្រកបមុខរបរចិញ្ចឹមជីវិតប៉ុណ្ណោះ ហើយមិនស្ថិតក្នុងគោលនយោបាយសេដ្ឋកិច្ចឡើយ។ ជាងនេះទៅទៀត បទបញ្ញត្តិក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនមានសារៈសំខាន់ក្នុងការការពារសម្រាប់ការងារក្រៅប្រព័ន្ធនោះទេ។ ដូចនេះ ការងារភាគច្រើនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមានភាពទន់ខ្សោយ ។

#### ១.៤.២.២. ទស្សនៈតាមបែបថ្មី

យោងតាមទស្សនៈបែបថ្មី ការងារក្រៅប្រព័ន្ធ មានដូចជា៖

- ការប្រកបមុខរបរដោយរកប្រាក់កម្រៃដោយខ្លួនឯង នៅក្នុងសហគ្រាសក្រៅប្រព័ន្ធ គឺសំដៅដល់អ្នកធ្វើការមិនចុះបញ្ជី។ អ្នកទាំងនោះមានដូចជា និយោជិត អ្នកធ្វើប្រតិបត្តិការអាជីវកម្មដោយខ្លួនឯង និងអ្នកធ្វើការនៅក្នុងគ្រួសារមិនយកប្រាក់កម្រៃ។
- ការងារគិតជាម៉ោង នៅក្នុងការងារក្រៅប្រព័ន្ធ រួមមាន និយោជិតនៃសហគ្រាសក្រៅប្រព័ន្ធ និងអ្នកធ្វើការទទួលប្រាក់ឈ្នួលក្រៅប្រព័ន្ធផ្សេងទៀតដូចជា កម្មករទទួលកម្រៃប្រចាំថ្ងៃ អ្នកស៊ីឈ្នួលតាមផ្ទះ អ្នកធ្វើការបណ្ដោះអាសន្នជាដើម។

តាមការកំណត់និយមន័យបែបថ្មី សេដ្ឋកិច្ចក្រៅប្រព័ន្ធរួមចំណែកដ៏សំខាន់ក្នុងផលិតផលក្នុងស្រុកសរុប ហើយវាមានទំនាក់ទំនងជាមួយសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ សេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើរតួនាទីក្នុងការស្រូបទាញកម្លាំងពលកម្មនៃសហគ្រាសក្នុងប្រព័ន្ធដែលគ្មានសមត្ថភាព។

#### ១.៤.២.៣. ការកំណត់និយមន័យដោយសកម្មភាព

ការកំណត់និយមន័យរបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយសកម្មភាព គឺផ្អែកទៅលើទស្សនៈតាមបែបបុរាណ។ សហគ្រាសមួយចំនួនត្រូវបានចាត់ទុកថាជាសហគ្រាសក្រៅប្រព័ន្ធ ព្រោះសហគ្រាសទាំងនោះ កម្រនឹងអនុលោមទៅតាមបទបញ្ញត្តិអាជីវកម្មកំណត់ដោយរដ្ឋាភិបាល ដូចជាការបង់ពន្ធ លក្ខខណ្ឌការងារ និងការសុំអាជ្ញាប័ណ្ណធ្វើអាជីវកម្ម។ ទន្ទឹមនឹងនេះ សហគ្រាសក្រៅប្រព័ន្ធ មិនត្រឹមតែជាភ្នាក់ងារដែលស៊ីឈ្នួលពលកម្មប៉ុណ្ណោះទេ ថែមទាំងកាន់កាប់និងធ្វើការដោយខ្លួនឯងទៀតផង។ លើសពីនេះ ការប្រកបការងារដោយខ្លួនឯងរួមមាន អ្នកលក់ដូរតាមដងផ្លូវសាធារណៈ អ្នកបើកបរតាក់ស៊ី និងអ្នកយកផ្ទះខ្លួនធ្វើអាជីវកម្មជាដើម។ ម៉្យាងវិញទៀត ការប្រកបរបររកស៊ីរបស់ពួកគាត់ កម្រនឹងប្រើប្រាស់ប្រព័ន្ធទិន្នន័យណាស់។

### ១.៤.៣. ចំណែកថ្នាក់នៃការងារក្រៅប្រព័ន្ធ

#### ១.៤.៣.១. ការងារក្រៅប្រព័ន្ធក្នុងទីផ្សារការងារ

ទ្រឹស្ដីនៃទីផ្សារការងារបានផ្ដល់នូវមធ្យោបាយមួយ ដើម្បីយល់ដឹងពីទីតាំងនៃការងារក្រៅប្រព័ន្ធនៅក្នុងទីផ្សារការងារ។ ទ្រឹស្ដីនេះបានបែងចែកទីផ្សារពលកម្មជា៤ផ្នែកសំខាន់គឺ ផ្នែកបឋម ផ្នែកបន្ទាប់បន្សំ ផ្នែកក្រៅផ្លូវការ និងផ្នែកខុសច្បាប់។ ផ្នែកនីមួយៗបង្ហាញនូវលក្ខណៈខុសពីគ្នានៃចំណាត់ថ្នាក់ក្នុងសង្គម។

- ផ្នែកបឋម (Primary sector) គឺសំដៅលើការងារដែលត្រឹមត្រូវ និងទទួលបានប្រាក់ខែដែលមានពន្ធអាករនិងគ្រប់គ្រងដោយច្បាប់។ឧទាហរណ៍ៈការងារក្នុងការិយាល័យ។
- ផ្នែកបន្ទាប់បន្សំ (Secondary sector) គឺសំដៅទៅលើការងារដែលមានសុវត្ថិភាពទាបជាងការងារក្នុងផ្នែកបឋម និងមិនមានការគ្រប់គ្រងតាមច្បាប់ត្រឹមត្រូវ។ឧទាហរណ៍ៈការងារដែលទទួលបានប្រាក់កម្រៃទាបក្នុងវិស័យសេវាកម្ម។
- ផ្នែកក្រៅប្រព័ន្ធ (Informal sector) គឺសំដៅទៅលើការងារដែលប្រមូលផ្តុំដោយអ្នកដែលគ្មានសមត្ថភាពឈានជើងចូលក្នុងការងារផ្នែកបឋម និងបន្ទាប់បន្សំ។ ការងារប្រភេទនេះ រួមបញ្ចូលនូវអ្នកដែលគ្រប់គ្រងមុខជំនួញតូចដោយខ្លួនឯងដោយប្រើប្រាស់តែសាច់ប្រាក់សុទ្ធ ឬអ្នកដែលធ្វើការឱ្យនិយោជក ប៉ុន្តែមិនត្រូវបានកត់បញ្ចូលក្នុងបញ្ជីការងារ។
- ផ្នែកខុសច្បាប់ (Illegal sector) គឺសំដៅលើការងារដែលស្ថិតនៅក្រៅប្រព័ន្ធច្បាប់ ឬការងារដែលទទួលបានប្រាក់ចំណូលដោយសកម្មភាពក្នុងបទឧក្រិដ្ឋ។

**តារាង ១៖ ផ្នែកនៃទីផ្សារការងារ**

| ផ្នែកបឋម | ផ្នែកបន្ទាប់បន្សំ | ផ្នែកក្រៅប្រព័ន្ធ | ផ្នែកខុសច្បាប់ |
|---|---|---|---|
| – ប្រាក់ខែខ្ពស់<br>– សុវត្ថិភាពខ្ពស់<br>– គ្រប់គ្រងបានល្អ | – ប្រាក់ខែទាប<br>– សុវត្ថិភាពទាប<br>– គ្រប់គ្រងមិនសូវល្អ | – ការងារផ្ទាល់ខ្លួន<br>– ការងារធម្មតា<br>– មិនបានគ្រប់គ្រង | – បទឧក្រិដ្ឋ<br>– មិនបានគ្រប់គ្រង |

ប្រភព៖ ILO, 2002.

#### ១.៤.៣.២.. បរិបទនៃការងារក្រៅប្រព័ន្ធ

ការធ្វើចំណាត់ថ្នាក់នៃការងារក្រៅប្រព័ន្ធមួយទៀត ត្រូវបានបង្ហាញតាមរយៈបរិបទនៃការងារ។

**តារាង ២៖ រចនាសម្ព័ន្ធនៃចំណាត់ថ្នាក់ការងារក្រៅប្រព័ន្ធ**

| | ការងារចម្បង | ការងារបន្ទាប់បន្សំ |
|---|---|---|
| **អ្នកធ្វើការឱ្យអ្នកដទៃ** | – គ្មានការចុះបញ្ជី<br>– ទទួលប្រាក់កម្រៃនិងគ្មានពន្ធ | – ធ្វើការបន្ថែមម៉ោងនៃចុងសប្តាហ៍ ឬពេលរសៀល (គ្មានការគិតពន្ធ) |

| | **អ្នកគ្រប់គ្រងអាជីវកម្មផ្ទាល់ខ្លួន** | **ការងារដាច់ដោយឡែកពីគេ** |
|---|---|---|
| **អ្នកធ្វើអាជីវកម្មផ្ទាល់ខ្លួន** | – ដោះដូរតែសាច់ប្រាក់<br>– ដំណើរការទៀងទាត់<br>– មុខរបរគឺជាប្រភពចម្បងនៃចំណូល<br>– វិនិយោគចំណូលទៅក្នុងមុខរបរ | – ធ្វើការតាមរដូវ<br>– ជួយកាត់បន្ថយការចំណាយក្នុងគ្រួសារតាមរយៈការផ្តល់នូវសេវាកម្ម ឬទំនិញ<br>– មុខរបរដែលតូចតាច |

ប្រភព៖ ILO, ២០០២។

អ្នកដែលធ្វើការឱ្យអ្នកដទៃអាចធ្វើការងារនោះក្នុងលក្ខណៈជាការងារចម្បង ឬគ្រាន់តែជាការងារបន្ថែមលើការងារចម្បងរបស់ពួកគេ។ ជាឧទាហរណ៍ និយោជិតទាំងឡាយធ្វើការនៅក្នុងសហគ្រាសធុនតូច មធ្យម ឬធំ ដែលមិនមានឈ្មោះក្នុងបញ្ជីការងារត្រឹមត្រូវ ហើយទទួលបានប្រាក់កម្រៃប្រចាំថ្ងៃ និងមិនត្រូវបានទូទាត់ពន្ធ។ ម្យ៉ាងវិញទៀត បុគ្គលិកធ្វើការថែមម៉ោងនៅចុងសប្តាហ៍ ឬពេលរសៀល ឬយកការងារទៅបន្ថែមនៅផ្ទះ ដើម្បីបង្កើនចំណូលរបស់ខ្លួន ត្រូវបានចាត់ទុកជាបុគ្គលិកដែលគ្មានឈ្មោះក្នុងបញ្ជី។

អ្នកដែលធ្វើការងារផ្ទាល់ខ្លួនរួមមានអ្នកដែលគ្រប់គ្រងលើអាជីវកម្មផ្ទាល់ខ្លួនក្នុងទម្រង់ជាប្រភពចម្បងនៃប្រាក់ចំណូលគ្រួសារ ឬបន្ទាប់បន្សំ។ ឧទាហរណ៍៖ មីង សុខ គ្រប់គ្រងលើអាជីវកម្មបោកអ៊ុតដោយខ្លួនឯង ដែលមុខរបរនេះជាមុខរបរចម្បងរបស់គាត់ក្នុងការរកប្រាក់ចំណូលក្នុងក្រុមគ្រួសារ។ អ្នកដែលធ្វើវត្ថុអនុស្សាវរីយ៍លក់តែនៅក្នុងពេលបុណ្យទាន ឬលក់ទៅឱ្យមិត្តភក្តិក៏ជាឧទាហរណ៍នៃអ្នកធ្វើអាជីវកម្មផ្ទាល់ខ្លួន។

### ១.៤.៤. ចរិតលក្ខណៈនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

#### ១.៤.៤.១. ស្របច្បាប់ ឬ ផ្ទុយពីច្បាប់

សកម្មភាពការងារក្រៅប្រព័ន្ធ ត្រូវបានវែកញែកថាស្របច្បាប់ ឬខុសច្បាប់ដោយផ្អែកលើទំនិញ ឬសេវាកម្មដែលផលិតឬដោះដូរ។ ឧទាហរណ៍៖ ការលក់អាហារ សម្លៀកបំពាក់ ឬសេវា

កម្មថៃទាំក្មេង គឺជាទង្វើស្របច្បាប់ ប៉ុន្តែអាចកំណត់បានជាសកម្មភាពខុសច្បាប់នៅពេលដែលសកម្មភាពទាំងនោះមិនបានចុះបញ្ជីពាណិជ្ជកម្ម ឬគេចវេសន៍ការបង់ពន្ធជូនរដ្ឋ។

### ១.៤.៤.២. សាច់ប្រាក់ជាមធ្យោបាយនៃការដោះដូរ

នៅក្នុងការងារក្រៅប្រព័ន្ធ ឬសេដ្ឋកិច្ចក្រៅប្រព័ន្ធ សាច់ប្រាក់ ឬរូបិយប័ណ្ណត្រូវបានប្រើប្រាស់ជាមធ្យោបាយចម្បងក្នុងការដោះដូរ ជាជាងការប្រើប្រាស់នូវសែក ឬប័ណ្ណឥណទាន ដើម្បីចៀសវាងនូវការកត់ត្រាប្រតិបត្តិការក្នុងការទូទាត់សាច់ប្រាក់។

ម៉្យាងវិញទៀត ប្រតិបត្តិការខ្លះនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺផ្អែកទៅលើការផ្លាស់ប្តូរសេវាកម្ម ដែលត្រូវបានគេហៅថា ការទូទាត់តាមរយៈការដោះដូរអ្វីផ្សេង។ ឧទាហរណ៍៖ ជាងរថយន្តម្នាក់ មិនបានគិតឈ្នួលថ្លៃជួសជុលរថយន្តពីជាងជួសជុលទុយោទឹក ជាថ្នូរនឹងការដែលជាងជួសជុសទុយោទឹកត្រូវជួសជុលទុយោទឹកដែលខូចក្នុងបន្ទប់ទឹករបស់គាត់។ ការធ្វើបែបនេះ គឺដើម្បីបញ្ចៀសការកត់ត្រានូវប្រតិបត្តិការសាច់ប្រាក់។

### ១.៤.៤.៣. ប្រាក់ខែ ឬប្រាក់កម្រៃដែលគ្មានការចុះបញ្ជី

នៅពេលដែលការទូទាត់សាច់ប្រាក់មិនត្រូវបានកត់ក្នុងប្រតិបត្តិការ ប្រាក់ចំណូលនឹងមិនត្រូវបានកាត់ពន្ធអាករ។ ការធ្វើបែបនេះ ផ្តល់ផលចំណេញទាំងសងខាងដល់និយោជក និងនិយោជិត ត្រង់ថា ប្រាក់ចំណូលរបស់និយោជិត នឹងមិនត្រូវបានកាត់ពន្ធ ខណៈពេលដែលនិយោជកមិនចាំបាច់រាយការណ៍ដល់រដ្ឋាភិបាល ឬក្រសួងពាក់ព័ន្ធនូវចំនួននិយោជិតដែលខ្លួនជួលមកធ្វើការ។

### ១.៤.៤.៤. លក្ខខណ្ឌពលកម្ម ឬការងារ

ប្រភេទការងារដែលក្រៅប្រព័ន្ធ ត្រូវបានសម្គាល់តាមរយៈការងារដែលមានលក្ខណៈអន់ជាងការងារក្នុងប្រព័ន្ធ ត្រង់ចំណុចមួយចំនួនដូចជា ប្រាក់កម្រៃ សន្តិសុខសុវត្ថិភាព និងការការពារពីការកេងប្រវ័ញ្ចស្តង់ដារការងារ។ ឧទាហរណ៍៖ អ្នកធ្វើការនឹងត្រូវបានផ្តល់នូវប្រាក់កម្រៃទាបជាងអ្នកធ្វើការធម្មតា ម៉្យាងប្រាក់កម្រៃទាំងនោះមិនបានរួមបញ្ចូលនូវ ប្រាក់របបសន្តិសុខសង្គម ប្រាក់ធានារ៉ាប់រងសុវត្ថិភាព ដោយសារតែពួកគេធ្វើការដោយពុំបានចុះបញ្ជីការងារត្រឹមត្រូវតាមបទបញ្ញត្តិការងារ។

## ១.៤.៥. មូលហេតុនៃកំណើនសេដ្ឋកិច្ចក្រៅប្រព័ន្ធ

មូលហេតុនៃការកើនឡើងរបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ មានដូចជា៖

### ១.៤.៥.១. ការស្រូបយកកម្លាំងពលកម្មមានកំណត់

នៅក្នុងប្រទេសក្រីក្រភាគច្រើន អត្រានៃចំនួនប្រជាជនមានការកើនឡើង ដែលធ្វើឱ្យកើតមានឡើងនូវភាពលើសនៃកម្លាំងពលកម្ម នៅក្នុងទីផ្សារពលកម្ម។ វិស័យកសិកម្ម និងវិស័យក្នុងប្រព័ន្ធបានស្រូបយកកម្លាំងពលកម្មនៅមានកម្រិត។ ដូចនេះ កម្លាំងពលកម្មដែលនៅសល់ទំនេរគ្មានជម្រើសក្រៅពីប្រកបមុខរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រោះថាមុខរបរប្រភេទនេះត្រូវចំណាយដើមទុនតិច និងមិនត្រូវការការអប់រំខ្ពង់ខ្ពស់ដូចការងារដទៃ។

### ១.៤.៥.២. ឧបសគ្គក្នុងការឈានចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ

ការចំណាយច្រើនលើសលប់ និងបទបញ្ញត្តិរបស់រដ្ឋាភិបាល គួបផ្សំនឹងអំពើពុករលួយផ្សេងៗក្នុងការចាប់ផ្តើមបង្កើតអាជីវកម្ម ការផ្តល់សិទ្ធិអាជីវកម្ម ជាដើម គឺជារនាំងរាំងអាជីវករទាំងឡាយក្នុងការឈានជើងចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ជាក់ស្តែង នៅពេលដែលអាជីវករចង់ធ្វើការបើកអាជីវកម្មមួយ គាត់ត្រូវចំណាយខ្ពស់ក្នុងការចុះបញ្ជីពាណិជ្ជកម្ម និងតម្រូវឱ្យមានដើមទុនមួយចំនួន ដែលតម្កល់ក្នុងធនាគារពាណិជ្ជ ហើយការផ្តល់សិទ្ធិធ្វើអាជីវកម្មមានលក្ខណៈស្មុគស្មាញ និងចំណាយពេលវេលាច្រើន។ ទាំងនេះជាកត្តាដែលបង្ខំឱ្យប្រជាជននៅតែបន្តប្រកបមុខរបរស្ថិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

### ១.៤.៥.៣. កង្វះការយកចិត្តទុកដាក់ពីរដ្ឋាភិបាល

រដ្ឋាភិបាលនៃប្រទេសមួយចំនួន មិនសូវបានយកចិត្តទុកដាក់អំពីការរួមចំណែកនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងសេដ្ឋកិច្ចជាតិ ព្រមនឹងបញ្ហាដែលកើតមាននៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធឡើយ ព្រោះពួកគេជឿជាក់ថា សេដ្ឋកិច្ចក្រៅប្រព័ន្ធនឹងបាត់ដោយខ្លួនឯង នៅពេលដែលមានការរីកចម្រើននៃសេដ្ឋកិច្ច។ ដូចនេះរដ្ឋាភិបាលពុំមានវិធានការទប់ស្កាត់ ឬអន្តរាគមន៍ទៅលើសេដ្ឋកិច្ចក្រៅប្រព័ន្ធឡើយ។

### ១.៤.៥.៤. ភាពយ៉ាប់យ៉ឺននៃសេដ្ឋកិច្ច

ខណៈពេលដែលសេដ្ឋកិច្ចនៅក្នុងប្រទេស មួយចំនួនមានការធ្លាក់ចុះ ប្រជាជនមួយភាគត្រូវបានបាត់បង់ការងារ និងសម្រេចចិត្តធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយទទួលបាននូវប្រាក់កម្រៃទាប និងពុំទទួលបាននូវការការពារត្រឹមត្រូវ។ ការស្រាវជ្រាវមួយបានបង្ហាញថា ប្រជាជនជាង១.៨ពាន់លាននាក់ ឬលើសពីពាក់កណ្តាលនៃកម្លាំងពលកម្មក្នុងពិភពលោកកំពុងបម្រើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ចំនួននេះត្រូវបានទស្សន៍ទាយថានឹងកើនឡើងរហូតដល់ជាង២ភាគ៣នៃចំនួនកម្លាំងពលកម្មសរុបក្នុងពិភពលោកនាឆ្នាំ២០២០ បើសិនណាជាការងារមួយចំនួន

នៅតែបន្តបាត់បង់តាមរយៈការថយចុះនៃសេដ្ឋកិច្ច ព្រមជាមួយនឹងការវិលត្រឡប់នៃជនចំណាកស្រុកមកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធវិញ។ [12] យ៉ាងណាមិញ ទោះបីជាកំណើនសេដ្ឋកិច្ចក្នុងប្រទេសមានការកើនឡើងក៏ដោយ ក៏កំណើននៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតែមានការរីកធំធាត់ក្នុងតំបន់មួយចំនួននៃប្រទេសនោះ ជាពិសេសគឺប្រទេសកំពុងអភិវឌ្ឍន៍។ [13] ជាក់ស្តែង ទោះបីជាប្រទេសឥណ្ឌាមានកំណើនសេដ្ឋកិច្ចលើសពី៥ភាគរយក្នុងកំឡុងទសវត្សចុងក្រោយនេះក៏ដោយ ក៏គេសង្កេតឃើញថា ប្រជាជន៩នាក់ក្នុងចំណោម១០នាក់ ឬប្រហែលជា៣៧០លាននាក់ពុំមានការងារត្រឹមត្រូវក្នុងសេដ្ឋកិច្ចផ្លូវការ។

### ១.៤.៥.៥. ស្ត្រីភាគច្រើនបម្រើការនៅក្នុងទីផ្សារ

ក្រៅពីមុខរបរកសិកម្ម ស្ត្រីមានចំនួនកើនឡើងក្នុងទីផ្សារការងារ ដោយស្ត្រីទាំងនោះភាគច្រើន ប្រកបមុខរបរតូចតាចដោយខ្លួនឯង ឬជាម្ចាស់សហគ្រាសធុនតូច ហើយមានតែមួយភាគតូចប៉ុណ្ណោះដែលជាម្ចាស់សហគ្រាសក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ លើសពីនេះទៀត ការចូលរួមរបស់ស្ត្រីនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមានការកើនឡើង នៅពេលដែលគំនាបគ្រួសារ ក៏ដូចជាសង្គម មានការថយចុះ ដែលអនុញ្ញាតិឱ្យស្ត្រីមានសិទ្ធិចេញពីផ្ទះដើម្បីប្រកបមុខរបររកស៊ី។

បញ្ហាទាំងអស់ខាងលើនេះ នាំឱ្យមានការកើនឡើងនូវសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលបណ្តាលមកពីកង្វះយន្តការសមស្រប ដោយគួរតែបញ្ចូលកម្លាំងពលកម្មនៃអ្នកធ្វើការទាំងនោះឱ្យចូលទៅក្នុងសេដ្ឋកិច្ចជាតិវិញ។ សរុបមក សេដ្ឋកិច្ចក្រៅប្រព័ន្ធ មិនអាចស្ថិតស្ថេរបានយូរទេ ប៉ុន្តែវាមានសារៈសំខាន់ក្នុងការងារ និងមានសក្តានុពលក្នុងការបង្កើនចំណូលបានមួយកម្រិតថែមទៀត។ ម៉្យាងការកើនឡើងនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ បានជួយបំពេញនូវសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ក្រីក្រ ដោយផ្តល់ទំនិញ និងសេវាក្នុងតម្លៃថោក។ ជាងនេះទៅទៀត វាបានធ្វើអន្តរាគមន៍យ៉ាងល្អប្រសើរបំផុត ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ និងបង្កើនការងារដល់ប្រជាជន។

---

[12] Johannes Jotting, *Rising Informal Employment Will Increase Povert*, http://www.oecd.org/development/risinginformalemploymentwillincreasepoverty.htm (ថតចម្លងថ្ងៃទី១០ ឧសភា ២០១៧)។

[13] Johannes Jotting, Rising Informal Employment Will Increase Poverty, http://www.oecd.org/development/risinginformalemploymentwillincreasepoverty.htm (ថតចម្លងថ្ងៃទី១០ ឧសភា ២០១៧)។

## ១.៥. ទំនាក់ទំនងរវាងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសេដ្ឋកិច្ចក្នុងប្រព័ន្ធ

គ្រប់បណ្តាប្រទេសទាំងអស់ក្នុងពិភពលោក សេដ្ឋកិច្ចត្រូវបានស្គាល់ជាកត្តាលីករដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ នៅក្នុងសេដ្ឋកិច្ចនេះផងដែរ គេបែងចែកសេដ្ឋកិច្ចជាពីរបែបគឺ សេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

- សេដ្ឋកិច្ចក្នុងប្រព័ន្ធ គឺជាសេដ្ឋកិច្ចដែលស្ថិតនៅក្នុងក្របខណ្ឌច្បាប់ និងមានការទទួលស្គាល់ពីសង្គម អាជ្ញាធរសាធារណៈ ហើយទទួលបានការយកចិត្តទុកដាក់ពីសំណាក់រដ្ឋាភិបាល។
- សេដ្ឋកិច្ចក្រៅប្រព័ន្ធ គឺជាសេដ្ឋកិច្ចដែលស្ថិតនៅក្រៅក្របខណ្ឌច្បាប់ និងមិនមានការយកចិត្តទុកដាក់ពីរដ្ឋាភិបាល ឬអាជ្ញាធរសាធារណៈ។

ថ្វីត្បិតតែវាមានការបែងចែកក៏ដោយ ក៏សេដ្ឋកិច្ចទាំងពីរមានទំនាក់ទំនងគ្នា តាមរយៈទំនាក់ទំនងរវាងសហគ្រាសក្នុងប្រព័ន្ធ និងសហគ្រាសក្រៅប្រព័ន្ធ រួមនឹងនិយោជិតក្រៅប្រព័ន្ធនិងសហគ្រាសក្រៅប្រព័ន្ធ។

- **ទំនាក់ទំនងរវាងសហគ្រាសក្នុងប្រព័ន្ធ និងសហគ្រាសក្រៅប្រព័ន្ធ**

ប្រភពវត្ថុធាតុដើម និងទំនិញសម្រេច ដែលផ្គត់ផ្គង់ដល់សហគ្រាសក្នុងប្រព័ន្ធដោយផ្ទាល់ ឬដោយចម្លងការក្តី គឺភាគច្រើនជាសហគ្រាសក្រៅប្រព័ន្ធ ព្រោះនៅក្នុងទីផ្សារសេដ្ឋកិច្ចក្រៅប្រព័ន្ធមានការប្រកួតប្រជែងគ្នាខ្លាំង ជាហេតុធ្វើឱ្យតម្លៃទំនិញធ្លាក់ចុះ ដែលផ្តល់ភាពងាយស្រួលដល់សហគ្រាសក្នុងប្រព័ន្ធនូវភាពងាយស្រួលក្នុងការស្វែងរកការផ្គត់ផ្គង់វត្ថុធាតុដើម ឬទំនិញដែលមានតម្លៃថោកក្នុងតម្រូវការរបស់ខ្លួន។

- **ទំនាក់ទំនងរវាងនិយោជិតក្រៅប្រព័ន្ធ និងសហគ្រាសក្រៅប្រព័ន្ធ**

ដោយកម្លាំងពលកម្មនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមានភាពលើស ធ្វើឱ្យថ្លៃឈ្នួលពលកម្មរបស់ពួកគេមានតម្លៃទាប។ ហេតុដូចនេះ សហគ្រាសមួយចំនួនក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ អាចកាត់បន្ថយការចំណាយរបស់ខ្លួនលើបុគ្គលិកមួយចំនួន តាមរយៈការជួលកម្លាំងពលកម្មពីសេដ្ឋកិច្ចក្រៅប្រព័ន្ធជំនួសវិញ ដែលក្នុងនោះរួមមានអ្នកបោសសម្អាត អ្នកដឹកជញ្ជូន អ្នកបេះផ្លែឈើ។ល។

## ១.៦. អំពីសេដ្ឋកិច្ចក្រៅប្រព័ន្ធនៅកម្ពុជា

### ១.៦.១. ស្ថានភាពការងារ និងប្រភេទរបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធ

តាមរយៈការសិក្សាស្រាវជ្រាវ និងការបង្ហាញរបស់អង្គការពលកម្មអន្តរជាតិប្រចាំប្រទេស

កម្ពុជា គេបានធ្វើការបែងចែកឋានៈការងារជា ៤ លំដាប់ថ្នាក់ ដូចខាងក្រោម៖

• **និយោជក៖** ដំណើរការក្នុងសហគ្រាសមួយ ដោយធ្វើពាណិជ្ជកម្ម ឬប្រកបអាជីពមួយ ដែលនៅក្នុងអាជីពនោះ មានមនុស្សម្នាក់ ឬច្រើននាក់បានបោះទុនរកស៊ី ដែលត្រូវបានគេហៅថា **ថៅកែ**។ មានតែមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ (ប្រហែល ៨,១១០នាក់) ដែលត្រូវបានគេចាត់ទុកថាជា និយោជក និងក្នុងចំណោមនិយោជកទាំងនេះ បុរសមានរហូតដល់ពីរភាគបី។

• **អ្នកប្រកបរបររកស៊ីដោយផ្ទាល់ខ្លួន៖** ដំណើរការក្នុងសហគ្រាសពាណិជ្ជកម្ម ឬប្រកបអាជីវកម្មផ្ទាល់ខ្លួនដោយមិនបានជួលនិយោជិតដែលមានប្រាក់ឈ្នួលឡើយ។ ស្ត្រីមាននិន្នាការជាអ្នកប្រកបការងារ កាត់ដេរ តម្បាញ សិប្បកម្ម និងប្រកបការងារផ្ទាល់ខ្លួនដូចជាអាជីវកម្មជាដើម ។ រីឯបុរសវិញ ប្រកបការងារក្នុងអាជីវកម្មលក់ដូរ ជួសជុលយានយន្ត ការងារសំណង់ ជាងដែក ជាងឈើធ្វើតុ-ទូ-កៅអី និងសិប្បកម្ម។ អ្នកដទៃទៀត គឺជាអ្នកបើកបររថយន្តឈ្នួល អ្នករត់ម៉ូតូឌុប-ម៉ូតូកង់បី-រ៉ឺម៉កម៉ូតូ ឬកម្មករ។ល។

• **និយោជិត៖** ជាមនុស្ស ឬក្រុមមនុស្សដែលធ្វើការឱ្យនិយោជកសាធារណៈ ឬឯកជន ដើម្បីទទួលបានកម្រៃជាប្រាក់ឈ្នួល កម្រៃជើងសារ ឬកម្រៃទូទាត់ទៅតាមបរិមាណការងារជាសាច់ប្រាក់ ឬវត្ថុ។

• **អ្នកធ្វើការដែលមិនមានប្រាក់ឈ្នួល៖** ជាសមាជិកគ្រួសារចូលរួមចំណែកធ្វើការងារ ដោយមិនយកកម្រៃក្នុងសហគ្រាសសេដ្ឋកិច្ចមួយ ដែលដំណើរការដោយសាច់ញាតិរស់នៅក្នុងគ្រួសារជាមួយគ្នា។ សម្រាប់កន្លែងស្នាក់នៅ ចំណីអាហារ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដែលម្ចាស់អាជីវកម្មបានផ្តល់ដល់ពួកគេ គឺមិនត្រូវបានរាប់បញ្ចូលចាត់ទុកថាជាការទូទាត់ប្រាក់ឈ្នួលចំពោះកម្លាំងពលកម្មឡើយ។

### ១.៦.២. ប្រភេទមនុស្សធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ មានមុខរបរ និងការងារជាច្រើនរាប់ពាន់ប្រភេទផ្សេងៗគ្នា។ ទោះបីជាយ៉ាងនេះក្តី ឆ្លងតាមរយៈការសិក្សា និងការវិភាគទៅលើមុខរបរចម្រុះទាំងនោះ អង្គការពលកម្មអន្តរជាតិបានសម្រេចធ្វើការកំណត់ចំណាត់ថ្នាក់ និងបែងចែកប្រភេទចំពោះមុខរបររបស់សេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ ជាបីក្រុមធំៗគឺ៖

• **អ្នកប្រកបរបររកស៊ីដោយខ្លួនឯង៖** សំដៅដល់អ្នកដែលប្រកបការងារដោយខ្លួនឯង ឬធ្វើការតែឯង ឬរួមជាក្រុមជាមួយនិយោជិត ឬបុគ្គលិកដែល *មិនមានប្រាក់ឈ្នួល*។ ឧទាហរណ៍៖

អាជីវកម្មរត់គាត់ស៊ីពីរនាក់ប្តីប្រពន្ធដោយមានរថយន្តជាកម្មសិទ្ធិផ្ទាល់ខ្លួន ដែលប្តីជាអ្នកបើកបរ និងប្រពន្ធជាអ្នកហៅភ្ញៀវ និងប្រមូលលុយ។ ពួកគាត់ទាំងពីរនាក់ គឺជាអ្នកប្រកបរបររកស៊ីដោយខ្លួនឯង ពីព្រោះថា ពួកគាត់មិនបានស៊ីឈ្នួលបើកឡានឱ្យគេឡើយ ហើយពួកគាត់គឺជាគ្រួសារនឹងគ្នា ដែលប្តីជាតៃកុង និងប្រពន្ធជាកម្មករឡានដែលមិនបានយកប្រាក់ឈ្នួល។ ហេតុផលសំខាន់មួយទៀតនោះ គឺការប្រកបរបរអាជីវកម្មរបស់ពួកគាត់មិនបានទៅចុះបញ្ជីពាណិជ្ជកម្មទៀតផង។ ដោយរថយន្តនោះជាទុនវិនិយោគរបស់ពួកគាត់ផ្ទាល់ និងមិនបានស៊ីឈ្នួលបើកឱ្យថៅកែណាម្នាក់ឡើយ បែបនេះ នាំឱ្យគេអាចចាត់ទុកពួកគាត់ថាជាអ្នកប្រកបរបររកស៊ីដោយខ្លួនឯង។ បើទោះបីជាឡាននោះគាត់ជួលគេក៏ដោយ ក៏គេនៅតែអាចចាត់ទុកចាត់បញ្ចូលពួកគាត់ថា ជាអ្នកប្រកបរបររកស៊ីដោយខ្លួនឯងបានដដែល។ តទៅនេះ សម្រាប់អ្នកប្រកបរបររកស៊ីដោយខ្លួនឯងគួរតែត្រូវបានគេផ្លាស់មកហៅថាជា " **អាជីវករ** " វិញ ដោយសម្អាងថា ពួកគាត់បានយកដើមទុនផ្ទាល់របស់គាត់មករកស៊ីដោយឯករាជ្យ និងមានម្ចាស់ការលើខ្លួនឯង ហើយក៏មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកណាម្នាក់ដែរ។ ក្រុមអាជីវករ ទាំងនេះរួមមាន អ្នកលក់ដូរ អ្នកលក់ទូរស័ព្ទដៃ អ្នកលក់ដូរតាមចិញ្ចើមផ្លូវថ្នល់ អ្នករត់ម៉ូតូឌុប ម៉ូតូកង់បី អ្នកជាក់ស៊ីក្លូ ... ជាដើម ជាពិសេស អ្នកលក់ភេសជ្ជៈតាមរទេះ ដែលយើងនឹងលើកយកមកធ្វើជាកម្មវត្ថុសិក្សានៅក្នុងជំពូកក្រោយ។

- **ថៅកែក្រៅប្រព័ន្ធ៖** សំដៅដល់និយោជកនៃមីក្រូសហគ្រាស ឬសហគ្រាសធុនតូចក្រៅប្រព័ន្ធ។ ឧទាហរណ៍៖ ហាងលក់កាហ្វេ ដែលមានកម្មកររត់តុចំនួន ៥នាក់ ហើយកម្មករទាំងនោះត្រូវបានថៅកែទូទាត់ប្រាក់ខែឱ្យជារៀងរាល់ខែ។ ថៅកែដែលជាម្ចាស់ហាងកាហ្វេនោះ មិនបានចុះបញ្ជីអាជីវកម្ម និងសុំអាជ្ញាប័ណ្ណពីក្រសួងពាក់ព័ន្ធឡើយ។ ដូច្នេះមានន័យថា ហាងកាហ្វេខាងលើ ត្រូវបានគេចាត់ទុកជាហាងមួយដែលមានដំណើរការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលនាំឱ្យគេអាចនិយាយថាថៅកែហាងកាហ្វេជា *ថៅកែក្រៅប្រព័ន្ធ* ។
- **កម្មករក្រៅប្រព័ន្ធ៖** សំដៅដល់កម្មករ និយោជិត ឬអ្នកធ្វើការ ដែលស្ថិតនៅក្នុងមីក្រូសហគ្រាស ឬសហគ្រាសធុនតូចក្រៅប្រព័ន្ធ ឬអ្នកធ្វើការទាំងឡាយណាដែលមិនមាននិយោជកច្បាស់លាស់ ឬគ្មានកិច្ចសន្យាការងារច្បាស់លាស់ ដូចជា អ្នកបម្រើការងារតាមផ្ទះ អ្នកមៅការសំណង់ អ្នកលក់ដូរតាមចិញ្ចើមផ្លូវ ជាដើម។

### ១.៦.៣. ចរិតលក្ខណៈនៃអ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

#### ១.៦.៣.១. ការផ្លាស់ទីនៃប្រជាជន

ប្រជាជនដែលរស់នៅតាមតំបន់ជនបទ ភាគច្រើនប្រឈមមុខនឹងភាពក្រីក្រ និងឱកាសការងារមិនគ្រប់គ្រាន់ ក៏ដោយសារកង្វះនូវកម្មសិទ្ធិដីធ្លី ដែលជាហេតុធ្វើឱ្យការប្រកបការងារធ្វើកសិកម្មរបស់ពួកគេស្ថិតនៅក្នុងទ្រង់ទ្រាយតូច ដែលមិនអាចផ្គត់ផ្គង់នៅក្នុងគ្រួសារបានគ្រប់គ្រាន់។ ដោយសារតែបញ្ហាទាំងអស់នេះបានធ្វើឱ្យប្រជាជនមួយចំនួនធំសម្រេចចិត្តធ្វើចំណាកស្រុកពីកន្លែងកំណើតរបស់ខ្លួនដើម្បីទៅស្វែងរកការងារនៅទីប្រជុំជន និងតំបន់ទីក្រុងផ្សេងៗនៅក្នុងប្រទេស ក៏ដូចជាប្រទេសជិតខាងជាដើម។

នៅក្នុងប្រទេសកម្ពុជាអ្នកដែលធ្វើចំណាកស្រុកផ្លាស់ទីលំនៅ ភាគច្រើនគឺជាស្ត្រី។ ដោយសារតែមានការកើនឡើងនូវការងារក្នុងវិស័យឧស្សាហកម្មផ្នែកកាត់ដេរ និងមានភាពខ្វះខាតនៃការងារនៅក្នុងតំបន់ បានធ្វើឱ្យពួកគាត់ចាកចេញ និងផ្លាស់ប្តូរទីលំនៅទៅកាន់ទីក្រុង ដើម្បីរកប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ។ ស្របពេលជាមួយគ្នានេះដែរ ក្នុងចំណោមស្ត្រីទាំងនោះមួយចំណែកបានធ្វើការនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្នែកអាជីវកម្មខ្នាតតូច ដូចជា លក់មីឆា លក់បន្លែ និងលក់ភេសជ្ជៈតាមរទេះរុញជាដើម។ ក្រៅពីការងារ ក្រៅប្រព័ន្ធ ស្ត្រីមួយចំនួនដែលមានជំនាញការងារតិចតួច ក៏អាចប្រកបការងារនៅក្នុងវិស័យក្នុងប្រព័ន្ធផងដែរ ប៉ុន្តែភាគច្រើននៃអ្នកទាំងនោះងាយប្រឈមនឹងការបោកប្រាស់ ឬការកេងប្រវ័ញ្ចលើផលប្រយោជន៍ការងារ និងលក្ខខណ្ឌការងារ ពីព្រោះតែកង្វះនូវចំណេះដឹង ។

#### ១.៦.៣.២. ការប្រកបការងាររបស់ស្ត្រី

ឥរិយាបថសង្គម និងទំនៀមទម្លាប់ប្រពៃណីនៅក្នុងប្រទេសកម្ពុជា បានបណ្តាលឱ្យស្ត្រីមានឋានៈទាបនៅក្នុងសង្គម ហើយនាំឱ្យមានផលវិបាកដូចជា៖

- វិសមភាពយេនឌ័រក្នុងលទ្ធភាពទទួលបានការអប់រំ និងកម្រិតអក្ខរកម្មរបស់ស្ត្រីនៅមានកម្រិត
- ពលកម្មក្មេងស្រីមានអត្រាខ្ពស់
- វិសមភាពយេនឌ័រក្នុងការប្រើប្រាស់សេវាសាធារណៈ
- ស្ត្រីមានតំណែងតូចតាច និងមានសិទ្ធិតិចតួចក្នុងការសម្រេចចិត្តលើអ្វីមួយ
- នៅក្នុងវិស័យសេដ្ឋកិច្ចកម្ពុជា ភាពក្រីក្ររបស់ស្ត្រីមានកម្រិតខ្ពស់ជាងបុរស។

ភាពច្រើននៃមនុស្សដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវបានទទួលរងនូវការឈឺចាប់យ៉ាងខ្លាំងនៅក្នុងលក្ខខណ្ឌការងារ ជាពិសេសស្ត្រីដែលលបានទទួលរងពីឥទ្ធិពលសង្គមដោយការទទួលបានថ្លៃពលកម្មនៅក្នុងតម្លៃថោក និងរងការរិះគន់ពីសំណាក់មជ្ឈដ្ឋានជុំវិញខ្លួនយ៉ាងខ្លាំង។

កាងារក្រៅប្រព័ន្ធជាច្រើនដែលស្ត្រីនៅកម្ពុជាកំពុងធ្វើ រងការរិះគន់ពីមជ្ឈដ្ឋានជុំវិញខ្លួនដែលមានដូចជា ការងារជាស្ត្រីផ្សព្វផ្សាយស្រាបៀរ ស្ត្រីបំរើសេវាតាមផ្ទះ អ្នកលក់ដូរតូចតាច(អ្នកលក់ទឹកភេសជ្ជៈតាមរទេះនៅទីក្រុង) ជាដើម។

- **ការងារជាស្ត្រីផ្សព្វផ្សាយស្រាបៀរ**

ស្ត្រីដែលលក់ស្រាបៀរ គឺតែងតែងាយទទួលរងគ្រោះដោយការរំលោភលើផ្លូវភេទពីភ្ញៀវភាគច្រើន តាមរយៈម្ចាស់ភោជនីយដ្ឋាន អ្នកគ្រប់គ្រង និងតាមរយៈប្រតិបត្តិករផ្សេងៗទៀត ដែលបញ្ហាទាំងនេះបានធ្វើឱ្យស្ត្រីមានអារម្មណ៍អសុវត្ថិភាពនៅកន្លែងធ្វើការ។

- **អ្នកលក់ដូរតូចតាច**

ការលក់ដូរតូចតាច គឺជាប្រភពដ៏សំខាន់នៃប្រាក់ចំណូលរបស់ស្ត្រីដែលធ្វើការក្នុងវិស័យក្រៅប្រព័ន្ធនៅកម្ពុជា។ យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមនៃវិស័យជនបទ និងអង្គការនៅក្នុងតំបន់បានឱ្យដឹងថា ស្ត្រី៩០ភាគរយ ដែលមានអាយុចាប់ពី ៣០ឆ្នាំ ទៅ៦០ឆ្នាំជាអ្នកលក់ដូរតាមដងផ្លូវ។

### ១.៦.៤. បញ្ហាប្រឈមក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

សកម្មភាពសេដ្ឋកិច្ចក្រៅប្រព័ន្ធ គ្មានការគ្រប់គ្រងដោយច្បាប់ និងការពារបានល្អនៅឡើយ ហើយការគ្រប់គ្រងបទបញ្ញត្តិនៅមានលក្ខណៈមិនច្បាស់លាស់ទៀតនោះ។ ជាលទ្ធផលអ្នកធ្វើការក្រៅប្រព័ន្ធបានប្រឈមមុខនឹងបញ្ហាជាច្រើន ជាពិសេសស្ត្រីដែលលក់ដូរនៅតាមចិញ្ចើមផ្លូវ ដែលត្រូវបានរងនូវការរំខានពីសំណាក់អាជ្ញាធរសាធារណៈ។ បញ្ហានេះពួកគាត់បានជួបប្រទះជារៀងរាល់ពេលដែលប្រកបអាជីវកម្មនៅតាមដងផ្លូវ។ ភាពមិនច្បាស់លាស់ ឬកង្វះបទបញ្ញត្តិទីផ្សារ និងទីក្រុងលើការប្រើប្រាស់ទីសាធារណៈ និងតាមចិញ្ចើមថ្នល់ បានទុកឱកាសឱ្យអាជ្ញាធរសាធារណៈ ទារសំណូកពីពួកគេ។ អ្នកលក់ដូរតាមចិញ្ចើមផ្លូវត្រូវឱ្យលុយទៅកាន់អាជ្ញាធរជាថ្នូរនឹងការអនុញ្ញាតិឱ្យលក់ និងដាក់តាំងផលិផលរបស់ពួកគេ ដោយយកលេសថាជាថ្លៃសណ្តាប់ធ្នាប់សាធារណៈ។

### ១.៦.៤.១. ក្របខណ្ឌច្បាប់ និងបទបញ្ញត្តិក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ប្រសិនបើក្រឡេកមកមើលផ្នែកច្បាប់ និងបទបញ្ញត្តិផ្សេងៗនៅកម្ពុជា បទបញ្ញត្តិរបស់រដ្ឋាភិបាល បានបន្ថែមបន្ទុកផ្សេងទៀតដល់ប្រជាជនដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដូចជាអំពើពុករលួយ ការិយាល័យធិបតេយ្យ និងការចំណាយខ្ពស់ក្នុងប្រតិបត្តិការអាជីវកម្ម។ ដើម្បីធ្វើឱ្យអាជីវកម្មស្ថិតនៅក្នុងប្រតិបត្តិការត្រូវចុះបញ្ជី នៅក្រសួងមានសមត្ថកិច្ចជាច្រើន ដូចជាក្រសួងពាណិជ្ជកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ធានាលេខអត្តសញ្ញាណ ពន្ធប៉ាតង់ និងពន្ធអាករលើតម្លៃបន្ថែម ក្រសួងការងារសម្រាប់អនុម័តលើបទបញ្ជាផ្ទៃក្នុង និងក្រសួងពាក់ព័ន្ធដទៃទៀត ប្រសិនបើសកម្មភាពអាជីវកម្មទាក់ទងនឹងក្រសួងទាំងនោះ។ ករណីសហគ្រាសជាច្រើនបានជ្រើសរើសយកសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងប្រតិបត្តិការអាជីវកម្មដោយគ្មានការអនុញ្ញាតិ និងចុះបញ្ជីត្រឹមត្រូវ ដើម្បីចៀសវាងនូវបទបញ្ញត្តិដ៏ស្មុគស្មាញនានា និងការចំណាយខ្ពស់លើការចុះបញ្ជី។

ការគេចពន្ធ និងកង្វះទំនុកចិត្តលើតម្លាភាព ក្នុងការគ្រប់គ្រងរបស់រដ្ឋាភិបាលជំរុញឱ្យមានការមិនគោរពច្បាប់។ ភាពងាយរងគ្រោះរបស់អ្នកធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធកើនឡើងទ្វេដង ពួកគេមិនអាចគោរពតាមច្បាប់ទាំងនោះបានទេ ដោយហេតុថាពួកគេមានចំណូលទាប និងមិនទៀងទាត់។ ម្យ៉ាងទៀត ពួកគេតែងតែរងនូវការរំខាន និងការគំរាមកំហែងពីអាជ្ញាធរសាធារណៈ ទាំងសំណូក និងការគាបសង្កត់ផ្សេងៗ។

### ១.៦.៤.២. បញ្ហាទាក់ទងនឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធ

ក្រោមច្បាប់ការងារបច្ចុប្បន្ន អ្នកធ្វើការក្រៅប្រព័ន្ធមិនអាចទទួលកិច្ចការពារតាមផ្លូវច្បាប់ ឬពីសង្គមឡើយនៅក្នុងលក្ខខណ្ឌការងារក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

ស្ត្រីក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ស្រូបយកមួយផ្នែកធំនៃការងារអាជីវកម្មផ្ទាល់ខ្លួន និងប្រភេទការងារផ្សេងៗដែលទទួលបានប្រាក់កម្រៃ ដែលអាចផ្គត់ផ្គង់ជីវភាពគ្រួសារបានមួយចំណែក។ ទាំងនេះបានន័យថា ឱកាសរបស់ស្ត្រីក្នុងការរកប្រាក់នៅមានកម្រិត ហើយភាគច្រើនពឹងផ្អែកលើបុរសនៅក្នុងជីវភាពប្រចាំថ្ងៃ។ កង្វះប្រាក់កាស បានបណ្តាលឱ្យស្ត្រីដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពុំសូវមានលទ្ធភាពទទួលបានសេវាកម្មថែទាំសុខភាព ការអប់រំ និងសកម្មភាពសង្គមវប្បធម៌ និងនយោបាយផ្សេងៗទៀត។ ទន្ទឹមនឹងនេះផងដែរ អ្នកធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្រត្រូវបានគេប្រមូលផ្តុំ ហើយជាទូទៅ ប្រសិនបើប្រមូលផ្តុំវិញ សមាគមរបស់ពួកគេនៅមានភាពទន់ខ្សោយ កង្វះការយកចិត្តទុកដាក់ កង្វះធនធានមនុស្សដែលអាចបម្រើផលប្រយោជន៍ឱ្យ

សមាជិកនៅក្នុងក្រុម ជាពិសេសគ្មានប្រព័ន្ធឬលក្ខន្តិកៈច្បាស់លាស់។ អ្នកដែលធ្វើការនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធមានអាជីពនិងសកម្មភាពផ្សេងៗគ្នា ដែលធ្វើឱ្យពួកគេគ្មានពេលវេលា និងឱកាសគ្រប់គ្រាន់ក្នុងការប្រមូលផ្តុំ ដូចនេះពួកគេមានសិទ្ធ និងអំណាចតិចតួចនៅក្នុងសង្គម។

**១.៦.៥. សារៈសំខាន់នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ**

ទន្ទឹមនឹងការជួបប្រទះនូវបញ្ហាជាច្រើនរបស់ស្ត្រីពីការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពួកគេក៏បានទទួលបានមកវិញនូវអត្ថប្រយោជន៍មួយចំណែកផងដែរ។ ការងារនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការងារដល់ប្រជាជន និងបានរួមចំណែកយ៉ាងច្រើននៅក្នុងសេដ្ឋកិច្ចជាតិ។ ស្របពេលជាមួយគ្នានេះដែរ សេដ្ឋកិច្ចក្រៅប្រព័ន្ធបានផ្តល់នូវលក្ខណៈងាយស្រួលដល់ស្ត្រី ក្នុងការឈានចូលទៅក្នុងទីផ្សារជាងទីផ្សារនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដោយនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធតម្រូវឱ្យមានការចុះបញ្ជីអាជ្ញាបណ្ណ និងបង់ពន្ធជូនរដ្ឋជាដើម។ ផ្ទុយមកវិញចំពោះអ្នកដែលធ្វើការនៅក្នុងទីផ្សារក្រៅប្រព័ន្ធ មិនតម្រូវឱ្យដូចទីផ្សារក្នុងប្រព័ន្ធនោះទេ ដោយអាជីវករដែលមានដើមទុនតិច និងកម្រិតនៃការអប់រំទន់ខ្សោយក៏អាចប្រកបមុខរបរបានដែរ។ ម៉្យាងទៀត ការងារទាំងនេះក៏បានផ្តល់ប្រាក់ចំណូលដល់គ្រួសារមួយចំណែក សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារបានមួយកម្រិត ព្រមទាំងធ្វើឱ្យស្ត្រីមានភាពម្ចាស់ការលើខ្លួនជាងមុន។

បន្ថែមពីលើនេះទៅទៀត ការកាត់បន្ថយភាពក្រីក្រនៅកម្ពុជានៅមានការលំបាកនៅឡើយ បើទោះបីជាកំណើនសេដ្ឋកិច្ចខ្លាំង ប្រហែលជា ៦ភាគរយក្នុងមួយឆ្នាំ (១៩៩៤ ដល់ ២០០៣) ក៏ដោយ ប៉ុន្តែអត្រានៃភាពក្រីក្រ បានកើនឡើងពី ៣៦ភាគរយរហូតដល់កម្រិតខ្ពស់ដែលសន្នឹងពី ៤០ភាគរយ ទៅ៤៥ភាគរយ។ ប្រជាជនដែលក្រីក្រ គឺអសមត្ថភាពក្នុងការឈានចូលក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដោយសារតែពួកគេមានការអប់រំទន់ខ្សោយ និងមូលធនតិច ធ្វើឱ្យប្រជាជនក្រីក្រគ្មានជម្រើសក្រៅពីប្រកបមុខរបរ នៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពីព្រោះថា សេដ្ឋកិច្ចក្រៅប្រព័ន្ធផ្តល់នូវការងារសមស្របសម្រាប់ពួកគាត់ ទោះបីជាគាត់ដែលពុំសូវមានចំណេះដឹងខ្ពស់ ឬមានដើមទុនតិចតួចក៏អាចប្រកបមុខរបរនេះដែរ។ ដូចនេះសេដ្ឋកិច្ចក្រៅប្រព័ន្ធមិនត្រឹមតែស្រូបយកប្រជាជនដែលមានចំណូលទាបនោះទេ វាថែមទាំងចូលរួមក្នុងការកាត់បន្ថយនូវភាពក្រីក្រ និងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ស្ត្រីដែលជាភេទទន់ខ្សោយ ដូចជាប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃនៅក្នុងគ្រួសារ។

# ជំពូកទី២
# អំពីស្ត្រីលក់ដូរតាមដងផ្លូវ
# ក្នុងរាជធានីភ្នំពេញ

# ជំពូកទី២
# អំពីស្ត្រីលក់ដូរតាមដងផ្លូវក្នុងរាជធានីភ្នំពេញ

អ្នកលក់ដូរតាមដងផ្លូវត្រូវបានកំណត់ថាជា អ្នកដែលរកស៊ីលក់ដូរនូវទំនិញនៅតាមដងផ្លូវសាធារណៈដោយគ្មានទីតាំងលក់(តូប)ត្រឹមត្រូវ និងអចិន្ត្រៃយ៍ដើម្បីប្រកបរបររកស៊ី។ អ្នកលក់តាមដងផ្លូវអាចត្រូវបានគេគិតថាជាអ្នកលក់ដែលនៅនឹងមួយកន្លែង លុះណាតែពួកគាត់រកស៊ីនៅលើទីតាំងសម្រាប់ថ្មើរជើង ឬកន្លែងទំនេរផ្សេងៗដែលត្រូវបានអនុញ្ញាតិឱ្យលក់ដោយពុំបានផ្លាស់ប្តូរទីតាំងរៀងរាល់ថ្ងៃ។ ប៉ុន្តែពួកគាត់ត្រូវបានចាត់ទុកជាអ្នកលក់ចល័ត បើសិនណាជាពួកគាត់ផ្លាស់ប្តូរទីតាំងលក់ជារៀងរាល់ពេល ដូចជាអ្នកលក់ទូលទំនិញលក់តាមកញ្ច្រែង អ្នករែកលក់ អ្នករុញរទេះលក់នំ ភេសជ្ជៈ ឬម្ហូបអាហារជាដើម ដោយពួកគាត់ត្រូវដើរចល័តពីទីតាំងមួយទៅទីតាំងមួយទៀតដើម្បីលក់ទំនិញរបស់គាត់។[14]

ចំនួនអ្នកដែលប្រកបមុខរបរតាមចិញ្ចើមផ្លូវបានកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងទីក្រុងធំៗក្នុងតំបន់អាស៊ី។ ជាក់ស្តែង ចំនួនអ្នកលក់តាមដងផ្លូវក្នុងទីក្រុងនៃប្រទេសឥណ្ឌាមានប្រហែល ២%នៃចំនួនប្រជាជនដែលរស់នៅក្នុងតំបន់នោះ (ប្រហែលនឹង១០លាននាក់)។ តួរលេខនេះក៏ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងនាពេលអនាគតផងដែរ។ របាយការណ៍បានបង្ហាញថា ចំនួនអ្នកលក់តាមដងផ្លូវបានកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ១៩៩៨។ វិបត្តិនេះមានឥទ្ធិពលយ៉ាងខ្លាំងដល់ការកើនឡើងនៃចំនួនអ្នកលក់តាមដងផ្លូវក្នុងប្រទេសមួយចំនួនដូចជា ថៃ សិង្ហបុរី និងហ្វីលីពីន ដែលតួរលេខច្បាស់ការមិនត្រូវបានបង្ហាញរួមទាំងប្រទេសកម្ពុជាផង (ពួកគាត់ពុំបានចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវជាហេតុធ្វើឱ្យពុំមានតួរលេខពិតប្រាកដអំពីចំនួនរបស់ពួកគាត់)។ ជាលទ្ធផល យើងអាចមើលឃើញថា អ្នកដែលបាត់បង់ការងារ និងពុំមានការងារធ្វើ បានសម្រេចចាប់យកការប្រកបមុខរបររកស៊ីតាមដងផ្លូវដើម្បីចិញ្ចឹមគ្រួសារ។[15]

## ២.១. ស្ថានភាពនៃស្ត្រីលក់ដូរតាមដងផ្លូវក្នុងរាជធានីភ្នំពេញ

យោងតាមការស្រាវជ្រាវកន្លងមកបានបង្ហាញថា អ្នកលក់ដូរតាមចិញ្ចើមផ្លូវទាំងអស់ប្រកបមុខរបរផ្សេងៗពីគ្នា ដែលភាគច្រើននៃអ្នកលក់ទាំងអស់លក់បន្លែនិងផ្លែឈើ (៨៣.២%)

[14] Bhowmik, K, S., *Street Vendor in Asia: A Review*។

[15] Ibid។

ហើយអ្នកដទៃទៀតលក់ចំណីអាហារលើរទេះ និងភេសជ្ជៈជាដើម។[16] ម៉្យាងភាគច្រើននៃអ្នកលក់ទាំងអស់សុទ្ធតែជាស្ត្រី ដែលចំនួនអ្នកលក់ជាបុរសមានត្រឹមតែ ៣% ប៉ុណ្ណោះក្នុងរាជធានីភ្នំពេញនាឆ្នាំ២០០៤។ [17] លើសពីនេះទៅទៀត ស្ត្រីលក់ដូរតាមចិញ្ចើមផ្លូវក្នុងរាជធានីភ្នំពេញភាគច្រើនមានអាយុចន្លោះពី ៣០ទៅ៥០ឆ្នាំ ដែលបានបង្ហាញយ៉ាងច្បាស់អំពីសារៈសំខាន់នៃមុខរបរនេះសម្រាប់ស្ថានភាពគ្រួសារក្រីក្រ ដែលគាត់អាចរកប្រាក់ចំណូលជាមធ្យម ៦០០០រៀល ក្នុងមួយថ្ងៃ។[18] ស្ត្រីទាំងនោះជាអ្នករ៉ាប់រងនូវជីវភាពក្នុងគ្រួសារ ដោយកម្រិតជីវភាពរបស់ពួកគាត់ស្ថិតនៅលើបន្ទាត់ក្រីក្រជាក់លាក់ មានន័យថាពួកគាត់អាចមានលទ្ធភាពត្រឹមតែផ្គត់ផ្គង់នូវចំណីអាហារ និងសម្លៀកបំពាក់សមរម្យដល់ក្រុមគ្រួសារតែប៉ុណ្ណោះ។

បន្ថែមពីលើនេះទៀត យើងឃើញថា កម្រិតអប់រំនៃអ្នកលក់ដូរតាមដងផ្លូវក្នុងរាជធានីភ្នំពេញទាំងអស់គឺមានភាពទាបជាងកម្រិតមធ្យម។ យោងទៅតាមជំរឿនក្នុងឆ្នាំ១៩៩៨ ប្រជាជនដែលជាស្ត្រីក្នុងរាជធានីភ្នំពេញ ៥០.៧% បានបញ្ចប់កម្រិតបឋមសិក្សា។ ប៉ុន្តែ ការស្រាវជ្រាវរបស់លោក Banwell បានបង្ហាញថា ត្រឹមតែ១២.៣%ប៉ុណ្ណោះដែលបានបញ្ចប់ការសិក្សាត្រឹមកម្រិតបឋម ហើយ៣៤.៨%ទៀតមិនទទួលបានការអប់រំទាល់តែសោះ។ ការសិក្សាបានបង្ហាញទៀតថា ៧៥%នៃអ្នកលក់ដូរតាមផ្លូវដែលត្រូវបានសម្ភាសន៍បានចូលរៀន ក៏ប៉ុន្តែមានត្រឹមតែ ១៨%នៃអ្នកទាំងនោះដែលបានបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សា។[19] ជារួម អ្នកលក់ដូរតាមដងផ្លូវទាំងអស់ ជាមធ្យមរៀនបានត្រឹមថ្នាក់ទី៣ តែប៉ុណ្ណោះ។[20] Banwell បានបង្ហាញថា ពួកគាត់ភាគច្រើនបានរៀបការហើយ និង ៨៦.១% នៃអ្នកឆ្លើយតបមានកូនក្នុងបន្ទុក៤នាក់ ស្របពេលដែល Agnello និង Moller បង្ហាញថាអ្នកឆ្លើយតបទាំងអស់មានកូនជាមធ្យម៤នាក់ក្នុងបន្ទុក ឬស្ថិតក្នុងចន្លោះពី២ទៅ៤នាក់។

---

[16] Banwell, S., *Vendor's voices: The story of women micro-vendors in Phnom Penh Markets and an innovative program designed to enhance their lives and livelihood*, (Phnom Penh: The Asia Foundation, 2001)។

[17] Agnello, F. & Moller, J., *Vendors, purses: Women micro entrepreneurs and their business needs, Phnom Penh, Cambodia*, (Phnom Penh: Urban Sector Group, 2004) ។

[18] Ibid។

[19] Ibid។

[20] Kusakabe, K., *Women's participation in the market: Women retail traders in Phnom Penh, Cambodia*, (Thailand: Asian Institute of Technology, 2011) ។

ជាពិសេស អ្នករកស៊ីតាមដងផ្លូវបានរួមចំណែកយ៉ាងសំខាន់ក្នុងប្រាក់ចំណូលគ្រួសារ ទោះបីជាពួកគាត់រស់នៅជាមួយស្វាមីក៏ដោយ។ ជាង៩០%នៃអ្នកទាំងអស់ បានរួមចំណែកលើសពី៥០% នៃប្រាក់ចំណូលក្នុងគ្រួសារ។ ក្រៅពីការរួមចំណែកក្នុងចំណូលគ្រួសារ ពួកគាត់ក៏មានឥទ្ធិពលផងដែរក្នុងការធ្វើការសម្រេចចិត្តទៅតាមអាយុរបស់ពួកគាត់។ ជាក់ស្តែង ជាង៧០% នៃអ្នកផ្តល់ចម្លើយដែលមានអាយុលើលពី៤០ធ្វើការសម្រេចចិត្តខ្លួនឯង។[21] នេះជាចំណុចមួយដែលធ្វើឱ្យស្ត្រីទាំងនោះមានអារម្មណ៍មួយថា ខ្លួនមានភាពម្ចាស់ការលើខ្លួនឯងដោយមិនចាំបាច់ពឹងលើបុរសជាស្វាមីនៅក្នុងគ្រួសារដើម្បីចិញ្ចឹម និងមើលថែរក្សាខ្លួន។ នៅក្នុងករណីមួយចំនួនដោយសារតែប្រជាជនខ្មែរ ប្រកាន់នូវផ្នត់គំនិតមួយដែលមិនឱ្យប្រុសៗធ្វើការងារផ្ទះសម្បែង ហើយទុកតួនាទីទាំងអស់ទៅលើស្ត្រីជាប្រពន្ធ ទោះបីពួកស្ត្រីដែលលក់ដូរតាមចិញ្ចើមផ្លូវជាស្ត្រីមេម៉ាយ ឬលែងលះគ្នា ក៏ពួកគាត់ពុំមានចំណាប់អារម្មណ៍ក្នុងការស្វែងរកគ្រួសារ ឬស្វាមីថ្មីដែរ ពីព្រោះពួកគាត់មានឯករាជ្យភាពលើខ្លួនឯង និងមិនត្រូវការជំនួយពីបុរស ដោយពួកគាត់ត្រូវរ៉ាប់រងបន្ទុកទាំងស្រុង ដូចជាស្វែងរកកម្រៃ និងធ្វើការងារផ្ទះជាដើម។ ការសិក្សាមួយបានបង្ហាញទៀត កត្តាដែលជំរុញទឹកចិត្តស្ត្រីទាំងនោះឱ្យខិតខំប្រកបមុខរបររកស៊ី គឺដើម្បីអនាគតរបស់កូនៗរបស់ពួកគាត់។ ពួកគាត់ចង់ឱ្យកូនៗរបស់ពួកគាត់ទទួលបានការអប់រំដូចកូនគេដទៃដែរ។

ម្យ៉ាងវិញទៀត មុខរបរលក់ដូរតាមចិញ្ចើមផ្លូវមិនមែនជាការងារបណ្តោះអាសន្នដែលពួកគាត់ប្រកបនោះទេ ពីព្រោះថា ភាគច្រើននៃពួកគាត់ប្រកបរបរនេះលើសពី១០ឆ្នាំ។ ពួកគាត់ធ្វើការជាច្រើនម៉ោង ដែលជាមធ្យម ១៣ម៉ោងក្នុងមួយថ្ងៃ ហើយរហូតដល់៧ថ្ងៃក្នុងមួយសប្តាហ៍ ដោយគ្មានថ្ងៃឈប់សម្រាក។ ទោះជាយ៉ាងណាក៏ដោយ ការដែលស្ថិតនៅក្រៅផ្ទះជាច្រើនម៉ោងក៏នាំឱ្យមានបញ្ហាខ្វះខាតមួយចំនួនផងដែរ ដូចជាពួកគាត់ខ្វះខាតពេលក្នុងការមើលថែរក្សាកូន ផ្តល់ភាពកក់ក្តៅដល់កូន គ្រប់គ្រងប្រៀនប្រដៅកូន ជាពិសេសពួកគាត់ពុំមានពេលវេលាក្នុងតាមដានការសិក្សានិងកិច្ចការផ្ទះរបស់កូនជាដើម ដែលជាហេតុធ្វើឱ្យកូនគាត់ខ្វះខាតនូវការយកចិត្តទុកដាក់មួយផ្នែកលើការសិក្សា បើទោះបីជាពួកគាត់មានលទ្ធភាពបញ្ជូនកូនទៅរៀនដើម្បីទទួលយកចំណេះដឹងឱ្យបានល្អប្រសើរជាងគាត់ក៏ដោយ។

[21] Banwell, S., *Vendor's voices: The story of women micro-vendors in Phnom Penh Markets and an innovative program designed to enhance their lives and livelihood*, (Phnom Penh: The Asia Foundation, 2001)។

## ២.២. កត្តាជំរុញឱ្យប្រកបមុខរបរតាមដងផ្លូវ

កត្តាជាច្រើនបានជំរុញឱ្យស្ត្រីទាំងនោះ ត្រូវសម្រេចចិត្តប្រកបមុខរបរលក់ដូរតាមចិញ្ចើមផ្លូវ ទោះបីវាជាមុខរបរមួយដែលមិនមានការចុះបញ្ជីត្រឹមត្រូវក៏ដោយ។ ការសិក្សាមួយបានបង្ហាញថា ៤១%នៃអ្នកដែលឆ្លើយតបនឹងការសម្ភាន៍សម្រេចចិត្តជ្រើសយកមុខរបរនេះដោយសារតែពួកគាត់ពុំមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបមុខរបរផ្សេងពីនេះ។ ខណៈពេលដែល ២៦%ទៀតបានឆ្លើយតបថា ពួកគាត់គ្មានជម្រើសផ្សេងក្រៅពីមុខរបរងាយស្រួលនេះ ពីព្រោះពួកគាត់ពុំមានចំណេះដឹងនិងជំនាញពិតប្រាកដ។ មុខរបរតែលក់តាមចិញ្ចើមផ្លូវជាប្រភពចំណូលដ៏សំខាន់សម្រាប់គ្រួសារ ដោយមិនតម្រូវឱ្យមានដើមទុនច្រើនក្នុងការចាប់ផ្តើមអាជីវកម្ម និងមិនចាំបាច់ត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្មផ្សេងៗដែលត្រូវចំណាយទាំងថវិកា និងពេលវេលាក្នុងការបំពេញសំណុំបែបបទផ្សេងៗ ព្រមទាំងអាចគេចវេសន៍ពីការបង់ពន្ធផ្សេងៗជាដើម។[22]

## ២.៣. ឥទ្ធិពលនៃការលក់ដូរតាមដងផ្លូវ

ស្ត្រីដែលលក់ដូរតាមចិញ្ចើមផ្លូវភាគច្រើនបានក្លាយទៅជាអ្នកដែលមានភាពម្ចាស់ការលើខ្លួនឯង និងមានទំនួលខុសត្រូវខ្ពស់ដោយសារតែពួកគាត់បានចេញមកប្រកបមុខរបរនៅខាងក្រៅផ្ទះ និងគេចផុតពីពាក្យចាស់ដែលរមែងនិយាយថា ស្ត្រីបង្វិលចង្ក្រានមិនជុំ។ នេះសបញ្ជាក់ឱ្យឃើញថា ស្ត្រីអាចរស់នៅដោយមិនចាំបាច់ពឹងផ្អែកទាំងស្រុងទៅលើបុរសជាស្វាមីទៀតឡើយ ហើយមានលទ្ធភាពក្នុងការស្វែងរកនូវប្រាក់កម្រៃដើម្បីទប់ទល់ជីវភាពគ្រួសារបាន។[23]

បើយើងក្រឡេកទៅមើលជ្រុងមួយនៃផលប្រយោជន៍ដែលអ្នកលក់តាមចិញ្ចើមផ្លូវផ្តល់ឱ្យយើងឃើញថា ការរកស៊ីតាមចិញ្ចើមផ្លូវមិនត្រឹមតែជាប្រភពចំណូលរបស់ពួកគាត់ ប៉ុន្តែវាជាសេវាកម្មដ៏ល្អបំផុតដែលបានផ្តល់ឱ្យអ្នកដែលរស់នៅក្នុងទីប្រជុំជន ជាពិសេសអ្នកដែលមានជីវភាពកម្រិតមធ្យម និងកម្រិតទាប។ អ្នកលក់ដូរទាំងនោះផ្តល់នូវទំនិញ និងសេវាកម្មក្នុងតម្លៃថោកសមរម្យដល់អតិថិជនរបស់ខ្លួនដែលជាអ្នកមានជីវភាពកម្រិតមធ្យម និងផ្តល់ភាពងាយស្រួលមួយកម្រិតដល់ពួកគាត់ខណៈដែលគាត់ពុំមានពេលគ្រប់គ្រាន់ក្នុងការធ្វើដំណើរទៅផ្សារ ឬចម្អិន

[22] Agnello, Francesca & Moller, *Vendor's Purses: Women Micro Entrepreneurs and their Business Needs, Phnom Penh, Cambodia*, (Phnom Penh: Urban Sector Group, 2004)។

[23] Banwell, S., *Vendor's voices: The story of women micro-vendors in Phnom Penh Markets and an innovative program designed to enhance their lives and livelihood*, (Phnom Penh: The Asia Foundation, 2001)។

អាហារខ្លួនឯង ព្រមទាំងផ្ដល់ដល់អ្នកដែលមានជីវភាពមិនសូវធូរធានូវទំនិញក្នុងតម្លៃដែលអាចទទួលយកបាន។[24]

## ២.៤. បញ្ហាប្រឈមផ្សេងៗ

ក្រៅពីផលប្រយោជន៍ដែលពួកគាត់បានទទួលពីមុខរបរនេះ និងអ្វីដែលគាត់បានផ្ដល់មកវិញដល់សង្គមវិញ ពួកគាត់ក៏ជួបប្រទះនូវបញ្ហាប្រឈមផ្សេងៗជាច្រើនផងដែរ។ បញ្ហាចម្បងដែលពួកគាត់ជួបប្រទះគឺ អ្នកលក់តាមចិញ្ចើមផ្លូវទាំងអស់ពុំមានទីតាំងសម្រាប់លក់ជាអចិន្ត្រៃយ៍ពិតប្រាកដមួយឡើយ ដែលជាហេតុធ្វើឱ្យគាត់ពិបាកក្នុងការរក្សាអតិថិជនរបស់ខ្លួន។ យោងតាមអនុក្រឹត្យលើការគ្រប់គ្រងសណ្ដាប់ធ្នាប់សង្គម ដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីកម្ពុជាទាំងពីររូប នៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ បញ្ជាក់ថា ការប្រកបមុខរបរតាមចិញ្ចើមផ្លូវជាអំពើល្មើសច្បាប់។ មុខរបរដែលគាត់រកស៊ីនេះត្រូវបានគិតថាជាមុខរបរមិនស្របតាមច្បាប់ និងពួកគាត់ត្រូវបានគេចាត់ទុកថាជាឧក្រិដ្ឋជន ព្រោះតែពួកគាត់ប្រកបរបរលក់ដូរដោយគ្មានការអនុញ្ញាតិត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ច និងជាទូទៅ ពួកគាត់ត្រូវបានទទួលរងការគំរាមកំហែងពីអាជ្ញាធរក្នុងតំបន់ដែលពួកគាត់រកស៊ី។ ជាការពិត ស្ត្រីដែលលក់ដូរតូចតាចនៅតាមចិញ្ចើមផ្លូវដែលស្ថិតនៅក្នុងសកម្មភាពក្រៅផ្លូវការផ្សេងៗ បានឱ្យដឹងថា ប្រសិនបើពួកគេមិនបង់ថ្លៃសេវាសាធារណៈឱ្យទៅអាជ្ញាធរទេនោះ ទំនិញរបស់ពួកគេនឹងត្រូវរឹបអូសឬបំផ្លាញ ហើយមិនអនុញ្ញាតឱ្យលក់ដូរនៅទីតាំងនោះឡើយ ។ ស្ត្រីជាច្រើនដែលប្រកបរបរនៅក្នុងវិស័យនេះ បានបង់ថ្លៃសំណូកឱ្យទៅអាជ្ញាធរទាំងនោះ ដោយសារតែភាពភ័យខ្លាចនៃការបាត់បង់អតិថិជនរបស់ខ្លួននិងមានការរំខានដល់ការរកស៊ីរបស់គាត់។ ពួកគាត់បន្ថែមទៀតថា បើសិនណាជាពួកគាត់អាចរកប្រាក់បានច្រើន ពួកគាត់ត្រូវបង់ថ្លៃសូកប៉ាន់ច្រើនដែរ។[25] ម៉្យាងទៀត មុខរបររបស់ពួកគាត់ពុំបានទទួលបានរបបសន្តិសុខសង្គម និងមិនទទួលបាននូវការធានារ៉ាប់រងទាំងសុខភាព និងអាយុជីវិតពីរាជរដ្ឋាភិបាលឡើយ។

លើសពីនេះទៅទៀត លុយកាក់ក៏ជាបញ្ហាដ៏ធំដែលគាត់ជួបប្រទះផងដែរ។ ពួកគាត់មានការលំបាកក្នុងការទាក់ទងជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងធនាគារ ដោយសារតែពួកគាត់ពុំសូវយល់ដឹងអំពីប្រតិបត្តិការ ផែនការកម្ចី សន្សំជាដើម ជាហេតុធ្វើឱ្យពួកគាត់ត្រូវប្រើប្រាស់

24 Bhowmik, K. S., *Street Vendor in Asia: A Review*។

25 Ibid។

ប្រាក់សន្សំទាំងអស់របស់ពួកគាត់ដើម្បីចាប់ផ្តើមអាជីវកម្មខ្លួន ឬត្រូវខ្ចីពីអ្នកចងការប្រាក់ក្នុងអត្រាការប្រាក់ខ្ពស់។ ការសិក្សាមួយរបស់ Kusakabe បានបង្ហាញថា អ្នកទាំងនោះធ្វើការរកស៊ីដើម្បីមូលហេតុបីសំខាន់គឺ ដើម្បីហូប ដើម្បីផ្តល់ការសិក្សាដល់កូន និងដើម្បីសងបំណុល។[26]

វាមាននូវបញ្ហាតូចៗជាច្រើនទៀតដែលអ្នកទាំងនោះជួបប្រទះដូចជា បញ្ហាអាកាសធាតុមិនទៀងទាត់ ជួនភ្លៀង ជួនក្តៅខ្លាំង ដែលជាហេតុបណ្តាលឱ្យអតិថិជនរបស់គាត់ថយចុះ ហើយគាត់ត្រូវសេសសល់នៅទំនិញត្រឡប់ទៅផ្ទះវិញ។ ពួកគាត់ក៏មានការលំបាកក្នុងការស្វែងរកនូវបង្គន់អនាម័យតាមទីសាធារណៈ ទឹកស្អាត និងបង្គន់អនាម័យតាមទីសាធារណៈដូចជានៅតាមដងផ្លូវដែលគាត់រកស៊ីមានសភាពហុយខ្លាំង ភក់ជ្រាំជាដើម ដែលជាហេតុធ្វើឱ្យទាំងអ្នកលក់ និងអ្នកទិញមានអារម្មណ៍គ្មានផាសុកភាព។

[26] Kusakabe, K., "Market Class and Gender Relation: A Case of Women Retail Traders in Phnom Penh", *International feminist Journal of Politics*, 5 (2003)។

# ជំពូកទី៣
# ការវិភាគ និងពិភាក្សាលើ
# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៣

# ការវិភាគ និងពិភាក្សាលើលទ្ធផលស្រាវជ្រាវ

ការវិភាគនេះធ្វើឡើង ដើម្បីពិនិត្យទៅលើស្ថានភាពនៃស្ត្រីលក់ភេសជ្ជៈតាមរទេះក្នុងរាជធានីភ្នំពេញ ក្នុងការលើកកម្ពស់ជីវភាពគ្រួសាររបស់ពួកគាត់ ដែលរួមមានចំណុចសំខាន់ៗមួយចំនួនដូចជា អាយុ រយៈពេលក្នុងការប្រកបមុខរបរ ស្ថានភាពគ្រួសារ ចំនួនអ្នកនៅក្នុងបន្ទុករបស់គាត់ កម្រិតអប់រំ កត្តាជំរុញឱ្យពួកគាត់សម្រេចចិត្តប្រកបមុខរបរនេះ បញ្ហានៅពេលចាប់ផ្តើមនិងពេលដំណើរការអាជីវកម្មដែលគាត់ជួបប្រទះ ព្រមជាមួយនិងប្រាក់ចំណូល-ចំណេញប្រចាំថ្ងៃ ប្រាក់ចំណាយក្នុងគ្រួសារប្រចាំថ្ងៃ និងប្រាក់សន្សំប្រចាំខែរបស់ពួកគាត់ដែលរកបានពីមុខរបរនេះ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារ។ បន្ថែមពីលើនេះទៀត វានឹងបង្ហាញឱ្យឃើញពីចំណុចខ្លាំង ចំណុចខ្សោយ ការគំរាមកំហែង និងឱកាសផ្សេងៗដែលស្ត្រីលក់ភេសជ្ជៈតាមរទេះជួបប្រទះ តាមរយៈការវិភាគSWOT។

## ៣.១. ការវិភាគបែបពិពណ៌នា

### ៣.១.១. ស្ថានភាពទូទៅនៃស្ត្រីលក់ភេសជ្ជៈតាមរទេះក្នុងរាជធានីភ្នំពេញ

#### ៣.១.១.១. អាយុ

ដោយពឹងផ្អែកលើលទ្ធផលដែលទទួលបាន ឃើញឃើញថា អ្នកផ្តល់ចម្លើយទាំងអស់មានអាយុក្នុងចន្លោះពី ២០ទៅ៦១ឆ្នាំ (គម្លាត ៤១ឆ្នាំ) ដោយអាយុជាមធ្យមរបស់ពួកគាត់គឺប្រហែល៣៦ឆ្នាំ ហើយភាគច្រើនមានអាយុ ៣០ និង៣៥ឆ្នាំ (ប្រេកង់៤)។ ក្នុងចំណោមអ្នកទាំងអស់ ពួកគាត់ភាគច្រើនមានអាយុចន្លោះពី២០ទៅ៤០ឆ្នាំ ដែលមានចំនួនសរុប ៤៣នាក់ (១៦នាក់ក្នុងចន្លោះពី ២០ទៅ៣០ និង១៧នាក់ក្នុងចន្លោះពី៣០ទៅ៤០ឆ្នាំ) ស្មើនឹង ៦៤៖%នៃចំនួនស្ត្រីលក់ភេសជ្ជៈដែលផ្តល់ចម្លើយទាំងអស់។ លើសពីនេះទៀត យើងសង្កេតឃើញថា ចំនួនអ្នកដែលមានអាយុពី៤០ទៅ៥០ឆ្នាំ មានរហូតដល់ ២៣ នាក់ និងអ្នកដែលមានអាយុលើសពី ៥០ឆ្នាំមានចំនួនតិចតួចបំផុត (៤នាក់)។ នេះសបញ្ជាក់ឱ្យឃើញថា អ្នកដែលមានអាយុក្រោម ៥០ឆ្នាំ មានសមត្ថភាពក្នុងការចេញទៅរកប្រាក់ចំណូលដើម្បីគ្រួសារ និងប្រឈមមុខទៅនឹងបញ្ហាផ្សេងៗនៅក្នុងការងារនេះ។ ប៉ុន្តែ នៅពេលដែលពួកគាត់មានអាយុលើសពី ៥០ឆ្នាំ ពួកគាត់ពុំសូវមានលទ្ធភាពក្នុងការចេញទៅប្រកបមុខរបររកស៊ីនោះទេ។

**ក្រាហ្វិក ១៖ អាយុ**




ប្រភព ៖ ទិន្នន័យចម្បង

យើងឃើញថា ទិន្នន័យនេះមានភាពប្រហាក់ប្រហែលទៅនឹងទិន្នន័យដែលលើកឡើងក្នុងឆ្នាំ ២០០៤ (ក្នុងជំពូកទី២) ដែលថាស្ត្រីដែលប្រកបមុខរបរនេះភាគច្រើនមានអាយុក្នុងចន្លោះពី ៣០ទៅ៥០ឆ្នាំ។

**៣.១.១.២. រយៈពេលប្រកបមុខរបរ**

ក្នុងចំណោមស្ត្រីលក់ភេសជ្ជៈតាមរទេះដែលផ្តល់ចម្លើយទាំងអស់ យើងឃើញថា ស្ត្រីដែលលក់ក្នុងចន្លោះពី ១ទៅ៥ឆ្នាំ មានចំនួនច្រើនជាងគេ រហូតដល់ ៣២នាក់ ដែលក្នុងនោះ ១២នាក់ ទើបតែប្រកបមុខរបរបានទើបតែមួយឆ្នាំ។ នេះក៏ព្រោះតែពួកគាត់សុទ្ធតែមានសភាពនៅវ័យក្មេង ហើយទើបសម្រេចចិត្តប្រកបមុខរបរនេះ (ទិន្នន័យក្នុងឧបសម្ព័ន្ធ៣ បានបង្ហាញថា គំរូតាងចំនួន១២ក្នុងចំណោម៤៨ ទើបតែប្រកបមុខរបរបានរយៈពេលមួយឆ្នាំ ហើយពួកគាត់មានអាយុក្រោម ៣៥ឆ្នាំ) ។ ចំណែកឯអ្នកដែលប្រកបមុខរបរនេះលើសពី៥ឆ្នាំ មានត្រឹមតែ១៦នាក់ ដែលប្រហែលនឹង ៣៣% ប៉ុណ្ណោះ។

ជារួម ទិន្នន័យដែលរកឃើញនេះបានបង្ហាញពីភាពផ្ទុយគ្នាស្រលះពីទិន្នន័យក្នុងជំពូកទី២ ដែលថា ស្ត្រីភាគច្រើនប្រកបមុខរបរនេះលើសពី១០ឆ្នាំ។ នេះក៏ព្រោះតែ មុខរបរលក់ភេសជ្ជៈតាមរទេះនេះ ទើបតែពេញនិយមខ្លាំងសម្រាប់ស្ត្រីដែលមានបំណងរកប្រាក់ចំណូលបន្ថែមសម្រាប់គ្រួសារ នាពេលបច្ចុប្បន្ននេះ។

ក្រាហ្វិក ២៖ រយៈពេលប្រកបមុខរបរ




ប្រភព ៖ ទិន្នន័យចម្បង

#### ៣.១.១.៣. ស្ថានភាពគ្រួសារ

យោងទៅតាមទិន្នន័យក្នុងក្រាហ្វិកបានបង្ហាញថា ភាគច្រើននៃអ្នកផ្ដល់ចម្លើយជាអ្នកដែលរៀបការរួច ដែលមានចំនួន ៣៧នាក់ ស្មើនឹង ៧៧.១% នៃចំនួនទាំងអស់ ខណៈពេលដែល

ក្រាហ្វិក ៣៖ ស្ថានភាពគ្រួសារ




ប្រភព ៖ ទិន្នន័យចម្បង

ស្ត្រីមេម៉ាយ(ប្ដីស្លាប់ចោល) និងអ្នកនៅលីវ មានចំនួន ៧នាក់ និង៤នាក់រៀងគ្នា។ ជាពិសេស ក្នុងចំណោមស្ត្រីទាំងអស់ពុំមានស្ត្រីណាម្នាក់ដែលបែកបាក់គ្រួសារ ដោយសារការលែងលះឡើយ។ នេះបានបង្ហាញថា ស្ត្រីដែលមានគ្រួសារបានចេញមកប្រកបមុខរបរដើម្បីស្វែងរកប្រាក់ចំណូលក្នុងការជួយផ្គត់ផ្គង់ជីវភាពគ្រួសារឱ្យបានល្អប្រសើរមួយកម្រិត។

ទិន្នន័យដែលរកឃើញ មានភាពស្របគ្នាទៅនឹងទិន្នន័យលើកឡើងនាពេលកន្លងមក ដោយភាគច្រើននៃពួកគាត់គឺជាស្ត្រីដែលមានគ្រួសារ។

### ៣.១.១.៤. ចំនួនអ្នកនៅក្នុងបន្ទុក

ក្នុងចំណោមគំរូតាងទាំងអស់ ចំនួនអ្នកនៅក្នុងបន្ទុកជាមធ្យមមាន ៤ នាក់។ ជាក់ស្តែងនៅក្នុងក្រាបបង្ហាញយ៉ាងច្បាស់ថា ៥០%នៃគំរូតាង (២៤នាក់ក្នុងចំណោម៤៨នាក់) រ៉ាប់រងលើអ្នកក្នុងបន្ទុកចន្លោះពី៤ទៅ៦នាក់ ហើយ ២៥%ទៀតមានអ្នកក្នុងបន្ទុកពី ២ទៅ៤នាក់។ ចំណែកឯអ្នកនៅសេសសល់មានចំនួនអ្នកក្នុងបន្ទុក ពី៦ទៅ៨នាក់ (ចំនួនធំបំផុតមានត្រឹម៨)។

ទិន្នន័យនេះមានភាពដូចគ្នាទៅនឹងទិន្នន័យកន្លងមកដូចបានបង្ហាញក្នុងជំពូកទី២ (ចំនួនអ្នកនៅក្នុងបន្ទុកជាមធ្យម ៤នាក់)។

**ក្រាហ្វិក ៤៖ ចំនួនអ្នកនៅក្នុងបន្ទុក**




ប្រភព ៖ ទិន្នន័យចម្បង

### ៣.១.១.៥. កម្រិតវប្បធម៌

ស្ថិតិបានបង្ហាញថា ចំនួនអ្នកដែលបានសិក្សាបញ្ចប់កម្រិតវិទ្យាល័យ (ថ្នាក់ទី១២) និងបឋមសិក្សា (ថ្នាក់ទី៦) មានចំនួនប្រហាក់ប្រហែលគ្នា (១៥នាក់ និង១២នាក់ ស្មើនឹង ៣១% និង ២៥%រៀងគ្នា)។ ដូចគ្នានេះដែរ អ្នកដែលបានបញ្ចប់ថ្នាក់អនុវិទ្យាល័យ (ថ្នាក់ទី៩) មានចំនួន ៩នាក់ (១៩%) ស្មើនឹងអ្នកដែលមិនបានទទួលការសិក្សាសោះ។ ក្នុងចំណោម៩នាក់នៃអ្នកដែលមិនបានទទួលការអប់រំ ៦នាក់មានអាយុលើសពី៥០ឆ្នាំ នេះក៏ព្រោះតែពួកគាត់បានកើតនៅក្នុងសម័យសង្គ្រាមជាដើម។ ម៉្យាងវិញទៀត ក្នុងចំណោមអ្នកទាំងនោះមានតែ២នាក់ប៉ុណ្ណោះដែលបានបញ្ចប់ការសិក្សាថ្នាក់មហាវិទ្យាល័យ (កម្រិតបរិញ្ញាបត្រ) ព្រោះពួកគាត់ត្រូវការសេរីភាពផ្ទាល់ខ្លួន។ នេះក៏បានបញ្ជាក់ថា អ្នកដែលបញ្ចប់ថ្នាក់បរិញ្ញាបត្រខ្លះ មានសមត្ថភាព ក្នុងការស្វែងរកការងារដែលល្អប្រសើរជាងនេះ ដើម្បីចិញ្ចឹមជីវិតទៅតាមជំនាញរបស់ពួកគេ។ ជារួម យើងអាចនិយាយបានថា ពួកគាត់ក៏ទទួលបានការអប់រំយ៉ាងហោចណាស់ត្រឹមថ្នាក់ទី៩ ស្របតាមស្តង់ដារអប់រំនៃព្រះរាជាណាចក្រកម្ពុជាដែរ។

**ក្រាហ្វិក ៥៖ កម្រិតវប្បធម៌**




ប្រភព៖ ទិន្នន័យចម្បង

ទិន្នន័យនេះ បានបង្ហាញពីភាពប្រែប្រួលខ្លាំងដែលពួកគាត់ភាគច្រើនទទួលបានការអប់រំខ្ពស់ជាងការដែលអ្នកស្រាវជ្រាវមុនៗធ្លាប់លើកឡើងថា ភាគច្រើននៃពួកគាត់រៀនបានត្រឹមបឋមសិក្សា ឬថ្នាក់ទី៣ប៉ុណ្ណោះ។

### ៣.១.២. កត្តាជំរុញឱ្យប្រកបមុខរបរលក់គ្រឿងសមុទ្រ

ក្នុងចំណោមគំរូតាងទាំងអស់បានឱ្យដឹងថា កត្តាដែលជំរុញឱ្យគាត់សម្រេចចិត្តប្រកបមុខរបរនេះដែលជាមុខរបរមួយនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ពីព្រោះគាត់មានភាពលំបាកក្នុងការឈានជើងចូលក្នុងការងារនៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ប្រហែលជា ៣៣% (១៦នាក់) នៃពួកគាត់ជួបប្រទះនូវការខ្វះខាតចំណេះដឹង និងជំនាញផ្សេងដែលមិនអាចឱ្យគាត់រកការងារផ្សេងធ្វើបាន។

ទន្ទឹមនឹងនេះ ប្រហែលជា ៣១% (១៥នាក់) ទៀត គិតថាមុខរបរនេះជាមុខរបរដែលងាយស្រួលក្នុងការរកប្រាក់ចំណូលសម្រាប់ទប់ទល់ជីវភាពគ្រួសារ ព្រមទាំងអាចជួយក្នុងការរកប្រាក់ចំណូលក្នុងគ្រួសារផងដែរ។ លើសពីនេះទៀត ប្រហែលជា ២១%ទៀត ចាប់យកមុខរបរនេះជាមុខរបរចម្បងក្នុងគ្រួសារតែម្តង ដែលរាល់ការចំណាយទាំងអស់ក្នុងគ្រួសារត្រូវពឹងផ្អែកទាំងស្រុងលើប្រាក់ចំណេញពីមុខរបរនេះតែម្តង។ ទិន្នន័យបានបង្ហាញផងដែរថា ចំនួនអ្នកដែលគេចវេសន៍ពីការបង់ពន្ធនិងការបំពេញបែបបទអាជីវកម្មផ្សេងៗមានតិចតួចបំផុត ដែលបង្ហាញយ៉ាងច្បាស់ថា ពួកគាត់ពុំបានយល់ដឹងអំពីបែបបទអស់ទាំងនេះឡើយ។

**ក្រាហ្វិក ៦៖ កត្តាជំរុញឱ្យគាត់ប្រកបមុខរបរលក់គេសដ្ឋ:តាមរទេះ**




ប្រភព ៖ ទិន្នន័យចម្បង

ម៉្យាងវិញទៀត វាអាចបណ្តាលមកពីកង្វះដើមទុនក្នុងការចាប់យកមុខរបរផ្សេងដែលត្រូវប្រើចំណាយដើមទុនច្រើនក្នុងការចាប់ផ្តើម និងដំណើរការអាជីវកម្ម (ដូចនៅក្នុងទ្រឹស្តីកន្លងមក)។ ជាក់ស្តែង ក្រាហ្វិក៧ បានបង្ហាញថា ប្រហែល៨៥%នៃអ្នកទាំងនោះពឹងផ្អែកទាំងស្រុងទៅលើប្រាក់សន្សំផ្ទាល់ខ្លួន (៥៦%) និងកម្ចីពីសាច់ញាតិបងប្អូន (២៩%)។ ពួកគាត់ពុំមានលទ្ធភាពក្នុងការស្វែងរកនូវដើមទុនច្រើនក្នុងការចាប់ផ្តើមអាជីវកម្ម ដូចជាការខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង

អ្នកចងការឡើយ ដោយសារតែពួកគាត់ត្រូវបង់ថ្លៃការប្រាក់ជាប្រចាំ ករណីគាត់សម្រេចចិត្តខ្ចីពីគ្រឹះស្ថានទាំងនោះ។

**ក្រាហ្វិក ៧៖ ប្រភពនៃដើមទុនសម្រាប់ចាប់ផ្តើមអាជីវកម្ម**




ប្រភព ៖ ទិន្នន័យចម្បង

### ៣.១.៣. បញ្ហាប្រឈមនានាដែលអ្នកលក់តាមរទេះជួបប្រទះ

នៅកំឡុងពេលប្រមូលព័ត៌មាន ទិន្នន័យដែលទាក់ទងនឹងបញ្ហាដែលពួកគាត់ជួបប្រទះទាំងក្នុងពេលចាប់ផ្តើម និងកំឡុងពេលដំណើរការអាជីវកម្មត្រូវបានប្រមូលយកផងដែរ។ លទ្ធផលចុងក្រោយដែលទទួលបានពីកម្រងសំណួរត្រូវបានបង្ហាញនៅក្នុងក្រាហ្វិក ៨ និង៩ខាងក្រោម។ ម៉្យាងទិន្នន័យនេះ មានភាពត្រឹមត្រូវទៅនឹងទិន្នន័យដូចបានរៀបរាប់ក្នុងជំពូកទី២ ស្ទើរតែទាំងស្រុង។

ទិន្នន័យក្នុងក្រាហ្វិក ៨ បានបង្ហាញថា ក្នុងពេលចាប់ផ្តើមអាជីវកម្ម ប្រហែលជា ៥០% នៃពួកគាត់បានជួបនូវបញ្ហាខ្វះដើមទុន ដោយសារតែគាត់ពឹងផ្អែកតែទៅលើប្រាក់សន្សំផ្ទាល់ខ្លួន និងខ្ចីពីសាច់ញាតិបន្តិចបន្តួចដើម្បីធ្វើជាដើមទុនក្នុងការរកស៊ី ទោះបីអាជីវកម្មនេះមិនសូវចំណាយដើមទុនច្រើនយ៉ាងណាក៏ដោយ។ លើសពីនេះទៀត ១៥%នៃពួកគាត់ពុំសូវមានជំនាញ និងពុំមានបទពិសោធន៍ក្នុងការលក់។ មិនត្រឹមតែប៉ុណ្ណោះ ដោយសារតែការចាប់ផ្តើមលក់ ពួកគាត់ពុំសូវយល់ដឹងអំពីស្ថានការណ៍ច្បាស់លាស់ ប្រហែលជា ១០%នៃពួកគាត់បានជួបប្រទះនូវ

ការបណ្តេញពីកន្លែងមួយទៅកន្លែងមួយទៀតពីសំណាក់អាជ្ញាធរសណ្តាប់ធ្នាប់ និងសន្តិសុខតាមហាងផ្សេងៗ។

**ក្រាហ្វិក ៨៖ បញ្ហាប្រឈមពេលចាប់ផ្តើមអាជីវកម្ម**




ប្រភព ៖ ទិន្នន័យចម្បង

ក្រៅពីបញ្ហាដែលពួកគាត់ជួបប្រទះនៅពេលចាប់ផ្តើមអាជីវកម្ម ពួកគាត់ក៏ជួបប្រទះនូវបញ្ហាផ្សេងៗទៀតក្នុងកំឡុងពេលប្រកបអាជីវកម្មផងដែរ។ ជាក់ស្តែង បញ្ហាចម្បងដែលគាត់ជួបប្រទះគឺលក់មិនដាច់ឬមិនសូវមានអតិថិជនទៅតាមថ្ងៃ ដែលធ្វើឱ្យនៅថ្ងៃខ្លះពួកគាត់ពុំទទួលបានប្រាក់ចំណេញសោះ ព្រមជាមួយនឹងការបណ្តេញចេញពីសំណាក់អ្នកសណ្តាប់ធ្នាប់ជាដើម នៅពេលដែលពួកគាត់កំពុងលក់ដូរ (លើសពី៣០%)។ លើសពីនេះទៅទៀត បញ្ហាអាកាសធាតុ ក៏ជាឧបសគ្គបន្ទាប់របស់ពួកគាត់ផងដែរ ដូចជាមេឃភ្លៀងខ្លាំង មេឃមិនសូវក្តៅជាដើម។ ចំណែកឯបញ្ហាដូចជា បន្ទុកគ្រួសារ និងការប្រមាថម៉ាកងាយពីសង្គមគឺមានតិចតួចបំផុត ព្រោះការងារនេះមិនបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់គាត់ និងគ្រួសារឡើយ។

### ក្រាហ្វិក ៩៖ បញ្ហាប្រឈមកំឡុងពេលប្រកបអាជីវកម្ម




ប្រភព ៖ ទិន្នន័យចម្បង

#### ៣.១.៤. ឥទ្ធិពលអវិជ្ជមានចំពោះគ្រួសារ

ខណៈពេលដែលស្ត្រីជាម្ដាយចេញទៅលក់ភេសជ្ជៈតាមរទេះតាមដងផ្លូវ ពួកគាត់ក៏បានបន្សល់នូវឥទ្ធិពលអវិជ្ជមានដល់គ្រួសារផងដែរ។ តាមទិន្នន័យបានបង្ហាញថា ប្រហែលជា ៣៧% នៃពួកគាត់ (១៨នាក់) បានទុកការងារផ្ទះចោលទាំងស្រុង ដោយចេញពីផ្ទះទៅរកស៊ីតាំងពីព្រលឹមទល់ព្រលប់។ ខណៈពេលដែលពួកគាត់មិននៅផ្ទះ ការងារទាំងអស់ត្រូវបានធ្វើវិញនៅពេលដែលគាត់ត្រឡប់មកពីរកស៊ីវិញ រួមទាំងការធ្វើម្ហូបអាហារផងដែរ។ មិនតែប៉ុណ្ណោះ ប្រហែលជា ២០% នៃពួកគាត់ ពុំមានពេលសម្រាកគ្រប់គ្រាន់ឡើយជារៀងរាល់ថ្ងៃ។ ឥទ្ធិពលអវិជ្ជមានបន្ទាប់ទៀតមានដូចជាកង្វះភាពកក់ក្ដៅដល់កូនៗ ដោយពុំមានពេលវេលាគ្រប់គ្រាន់ផ្ដល់ដល់កូនៗ និងគ្មានពេលសម្រាប់តាមដានការសិក្សារបស់កូន (ប្រហែល២០%) រួមនឹងឥទ្ធិពលអវិជ្ជមានដទៃទៀត។

**ក្រាហ្វិក ១០៖ ឥទ្ធិពលអវិជ្ជមានចំពោះគ្រួសារ**




ប្រភព ៖ ទិន្នន័យចម្បង

### ៣.១.៥. ការលើកកម្ពស់ជីវភាពគ្រួសាររបស់ស្ត្រីតាមរយៈប្រាក់ចំណូល

#### ៣.១.៥.១. ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃ

យោងតាមទិន្នន័យដែលទទួលបាន យើងឃើញថា ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃរបស់ស្ត្រីដែលចូលរួមផ្តល់ព័ត៌មានទាំងអស់ គឺប្រហែល ២០០,០០០រៀលប្រចាំថ្ងៃ (មធ្យម= ១៩៩,៥៨៣រៀល)។ ប៉ុន្តែបើយើងក្រឡេកទៅមើលចំណុចកណ្តាលនៃប្រាក់ចំណូលជាប្រចាំរបស់ពួកគាត់ (មេដ្យាន) គឺ ត្រឹមតែ ១៥០,០០០រៀលប៉ុណ្ណោះ ស្របពេលដែលប្រាក់ចំណូលដែលមានប្រេកង់ច្រើនជាងគេ (ម៉ូត=១០) គឺត្រឹមតែ ១០០,០០០រៀល ក្នុងចំណោមប្រាក់ចំណូលទាបបំផុតត្រឹមតែ ៥០,០០០រៀល និងប្រាក់ចំណូលខ្ពស់បំផុតរហូតដល់ ១,២០០,០០០រៀល។

**តារាង ៣៖ ប្រាក់ចំណូលជាមធ្យមប្រចាំថ្ងៃនៃស្ត្រីលក់ភេសជ្ជៈតាមរទេះ**

| | | | |
|---|---|---|---|
| គំរូតាង | ៤៨ នាក់ | គម្លាតស្តង់ដារ | ២២១,៣០១.៣៥៧ |
| មធ្យម | ១៩៩,៥៨៣.៣៣ រៀល | អតិបរិមា | ១,២០០,០០០ រៀល |
| ម៉ូត | ១០០,០០០ រៀល | អប្បបរមា | ៥០,០០០ រៀល |
| មេដ្យាន | ១៥០,០០០ រៀល | សរុប | ៩,៥៨០,០០០ រៀល |

ប្រភព ៖ ទិន្នន័យចម្បង

ប៉ុន្តែបើយើងក្រឡេកទៅមើលទិន្នន័យនៅក្នុងក្រាហ្វិក ១១ យើងឃើញថា ស្ត្រីប្រហែលជា៥០% អាចរកប្រាក់ចំណូលក្នុងចន្លោះពី៥០,០០០ទៅ ១៥០,០០០រៀល ហើយប្រហែលជា៣០%អាចរកប្រាក់ចំណូលបានក្នុងចន្លោះពី ១៥០,០០០ទៅ ២៥០,០០០រៀល ខណៈពេលដែលអ្នកដែលរកបានលើសពី ៣០០,០០០រៀលមានត្រឹមតែប្រហែល២០%ប៉ុណ្ណោះ។

ជារួម ប្រាក់ចំណូលជាមធ្យមប្រចាំរបស់ស្ត្រីលក់ភេសជ្ជៈតាមរទេះ គឺប្រហាក់ប្រហែលក្នុងចន្លោះពី ១០០,០០០ទៅ ១៥០,០០០រៀលទៅតាមតំបន់ដែលពួកគេលក់ដូរ។ វាមានការកើនឡើងខ្លាំងខុសពីអ្វីដែលអ្នកស្រាវជ្រាវមុនបានលើកឡើង (៦០០០រៀលក្នុងមួយថ្ងៃ)។

**ក្រាហ្វិក ១១៖ ប្រាក់ចំណូលជាមធ្យមក្នុងមួយថ្ងៃ**




ប្រភព ៖ ទិន្នន័យចម្បង

### ៣.១.៥.២. ប្រាក់ចំណេញជាមធ្យមប្រចាំថ្ងៃ

បន្ថែមពីលើប្រាក់ចំណូលមធ្យមរបស់ស្ត្រី យើងក៏បានសាកសួរនូវព័ត៌មានទាក់ទងនឹងប្រាក់ចំណេញជាមធ្យមប្រចាំថ្ងៃរបស់ស្ត្រីទាំងនោះ។ យើងឃើញថា ប្រាក់ចំណេញជាមធ្យមប្រចាំថ្ងៃរបស់ពួកគាត់ដែលទទួលបានពីមុខរបរនេះគឺប្រមាណ ៨០០.០០០រៀល ស្មើទៅនឹងប្រាក់ចំណេញដែលមានប្រេកង់ច្រើនជាងគេ ក្នុងចំណោមប្រាក់ចំណេញអប្បបរិមា ១០,០០០រៀល និងអតិបរិមា ៥០០,០០០រៀល។

**តារាង ៤៖ ប្រាក់ចំណេញជាមធ្យមប្រចាំថ្ងៃនៃស្ត្រីលក់ភេសជ្ជៈតាមរទេះ**

| | | | |
|---|---|---|---|
| មធ្យម | ៨១,៣៥៤.១៧ រៀល | គម្លាតស្តង់ដារ | ១០០,៧៥៦.៣៩២ |
| ម៉ូត | ៨០,០០០ រៀល | អតិបរិមា | ៥០០,០០០ រៀល |
| មេដ្យាន | ៥៥,០០០ រៀល | អប្បបរមា | ១០,០០០ រៀល |

ប្រភព ៖ ទិន្នន័យចម្បង

